
រង់ ធឿង
តែចាប់ស្រីម្នាក់...

# គេចាប់ស្ត្រីម្នាក់...

ផ្នែកអាថិកំបាំង

ស្នាដៃទី ៤១៩

របស់

អ្នកនិពន្ធ វង់ ផឿង

បោះពុម្ពជាថ្មីដោយ ស្រី ប៊ុនជន

រក្សាសិទ្ធ

ព.ស. ២៥៤៥ គ.ស. ២០០១

អារម្ភកថា

រឿង " គេចាប់ស្ត្រីម្នាក់ " គឺជារឿងមួយដែលទាក់ទងនឹងផ្នែកអាថិកំបាំងដ៏ជ្រាលជ្រៅបំផុត . ហើយដែលអ្នករងគ្រោះបានបរិយាយផ្ទាល់ដោយខ្លួនឯង ។ ជាការពិតណាស់ហើយ ប្រលោមលោក គឺតែងតែមានលក្ខណៈអណ្ដែងអណ្ដូង, រំជើបរំជួល, នឹងការកំប្លែងខ្លះ ដើម្បីឱ្យមានលក្ខណៈជាប្រលោមលោក ។ សៀវភៅនេះមានលក្ខណៈជា " ប្រលោមលោកផ្នែក អាថិកំបាំង " ដែលជាដំបូន្មានមួយ ឱ្យនារីទាំងឡាយមានការប្រយ័ត្នខ្លួន ... ពីព្រោះនារីគឺជារង្វង់បាញ់ទី១ ដែលបុរសប្រាថ្នាជាទីបំផុត ...

សូមឧទ្ទិសស្នាដៃនេះ ជូនដល់ព្រលឹងមិត្តយុវជនដែលបានបាត់បង់ជីវិតនៅក្នុងសមរភូមិ ហើយនិងជូនដល់យុទ្ធជនដែលកំពុងតស៊ូ សំរាប់អានកំសាន្តមួយរយៈកាល ...

ពាក្យថា " ខ្ញុំ " គឺជាសំដីបរិយាយរបស់នារីរងគ្រោះ ...

វង់-ធឿង

## ១

# វិចិត្រករ

ខ្ញុំបានមើលវិចិត្រករ កំពុងគូររូបលើផ្ទាំងក្រដាសស ដែលដាក់ ភ្ជាប់នឹងក្តារខៀនបញ្ឈរ ។ គឺជាយុវវិចិត្រករដ៏មានរូបឆោមផុត លោកិយ, កេសីពណ៌ ខ្មៅរួញអង្កាដី, ស្មាទូលាយ, ចង្កេះឆ្មារ ជា អត្តពលិក ។ វិចិត្រ, នេះជានាមរបស់គេ ។ ខ្ញុំគយគន់យុវបុរសនេះ យូរ, ដោយឥតធុញទ្រាន់ទាល់តែសោះ ហើយដួងចិត្តខ្ញុំរំភើបគ្រប់ៗគ្រា ...

កាលៈទេសៈនេះ គួរណាស់តែខ្ញុំទុកពេលឱ្យបុរសនេះ ធ្វើការ របស់ខ្លួន ក៏ប៉ុន្តែចំណង់នៃការដើរលេងរបស់ខ្ញុំ បានលុកទន្រ្ទានមកក្នុង ដួងចិត្តខ្ញុំ ។ ខ្ញុំជានារីក្រមុំពេញក្បាលទឹកដូចទឹកឃ្មុំដូច្នោះ ។ ខ្ញុំជាស្រី ហើយព្រះអាទិទេពពិតជា យកចុងឬស្សីមកសាងស្ត្រី ព្រោះតែហេតុ នេះហើយបានជាខ្ញុំនៅមិននឹងនសោះ ។

- បងវិចិត្រឯងមិនគិតជូនខ្ញុំទៅដើរកំសាន្តទេឬ ? ថ្ងៃនេះជា ថ្ងៃអាទិត្យ ... គេបង្កើតថ្ងៃអាទិត្យដើម្បីសម្រាកមិនថាអ៊ីចឹង ?

យុវជនបន្តការផាត់គំនូរតទៅទៀតដោយឥតងាកមើលមុខខ្ញុំឡើយ ។ ឥរិយាបថយ៉ាងដូច្នេះ គឺបន្ថែមកំហឹងរបស់ខ្ញុំឱ្យកាន់តែឆេះឆួលឡើង ។ ខ្ញុំប្រើនេត្រាដមុតពស់វែក សម្លក់សម្លឹងយុវបុសរ ពីក្រោយ, ក៏ប៉ុន្តែឥតប្រយោជន៏សោះ ។ ខ្ញុំដើរទៅជិតក្តារខៀន បញ្ឈរហើយខ្ញុំយកដៃកាន់ស្មាវិចិត្រករជាទី ស្រឡាញ់នេះ ។

បងវិចិត្រ គួរតែយល់ចិត្តអូនជាស្រីណាស់ ។ មួយអាទិត្យហើយដែលអូនមកកាន់ផ្ទះបង ដើម្បីមើលបងគូរគំនូរដោយ សង្ឃឹមថា កាលបើគូរផ្ទាំងគំនូរទី១រួចហើយ

បងនឹងនាំអូនដើរកំសាន្ត... ក៏ប៉ុន្តែអនិច្ចាផ្ទាំងទី២ ផ្ទាំងទី៣ រហូតដល់ទី៧រួចស្រេចបាច់អស់ ក៏បងនៅតែចាប់ផ្តើមផ្ទាំងទី៨ទៀត ... តើបង្ខំគូរឱ្យនរណា ក៏ច្រើនម្ល៉េះ ?

សម្រាប់ពិពណ៌ ដែលជប៉ុនគេនឹងធ្វើនៅពេលឆាប់ ៗ នេះ ! បងត្រូវតែខំសាងឈ្មោះបង ទោះបីពុំបានកម្រៃប៉ុន្មានក៏ដោយ !

- បើអញ្ចឹងនាំអូនទៅដើរលេងទៅ

- កុំបង្ខំបង !

- ស្អី, អូនបង្ខំបងឯង ? មួយអាទិត្យក្រោយពីការរង់ចាំរបស់ អូនដ៏អន្ទះអន្ទែង នៅក្នុងរោងជាងដ៏ក្រខ្វក់នេះ, ដោយបែកញើស ជោកខ្លួនហើយ ដែលឥតហ៊ានទៅណាសោះ ! ទីបំផុតរង្វាន់ដែល អូនបានទទួលពីបង គឺសម្តីដ៏អាក្រក់ឃោរឃៅដូច្នេះឬ ? គ្មានពាក្យ ទន់ភ្លន់សោះ , អូនតែងអភ័យទោសឱ្យបងជានិច្ច ពីព្រោះអូនយល់ថា សិល្បករស្រឡាញ់សិល្បៈរបស់ខ្លួន ។ អូនធ្លាប់អានសៀវភៅ ឃើញស្ត្រីម្នាក់ដែលស្រឡាញ់គូសង្សាររបស់ខ្លួន សុខចិត្តស្រាតទាំង អស់អង្គុយលើកៅអីមួយដើម្បីឱ្យសង្សារនោះគូរ ។ ម្នាក់ៗ ក៏សុទ្ធតែ ជោកជាំក្នុងសិល្បៈដូចគ្នា ។ បុរសជាសង្សារខិតខំសំអិតសំអាងគូររូប នារីជាសង្សារ ។ នារីជាសង្សារទ្រាំអង្គុយមិនហ៊ានកម្រើកដើម្បីឱ្យ បុរសជាសង្សារគូរ, ពេលវេលាកន្លងទៅអស់៣យប់៣ថ្ងៃ ដោយម្នាក់ៗឥតឃ្លាតពីករណីកិច្ចរបស់ខ្លួនឡើយ ហើយម្នាក់ៗ ភ្លេចបរិភោគបាយទាំងអស់គ្នា ។ ប៉ុន្តែបុរសជាគូរសង្សារ ដែលគេមានចលនាដៃនិងជើងនោះឈាមឥតស្លាក់ឡើយ ។ ទីបំផុត, នៅពេល ដែលគេគូរនឹងផាត់ផ្ទាំងគំនូរ រួចហើយស្ទុះទៅកេះសង្សារដើម្បីមកមើលសរសើររូបផ្ទាំងគំនូរនេះទាំងអស់គ្នា ។ អនិច្ចា ! នារីជាសង្សារ ក៏ដួលតូង ... នាងស្លាប់ព្រោះស្លាក់ឈាម ដោយឥតកម្រើកទាល់តែ សោះ ...

វិចិត្របែរមើលមុខខ្ញុំ ហើយឥតមានមនោសញ្ចេតនាអ្វីសោះ ។ តាមពិតបើពេលធម្មតាវិញ, វិចិត្រជាមនុស្សដែលមានសេចក្តីរំភើបណាស់ កាលបើដឹងរឿងរ៉ាវដូច្នេះ, ក៏ប៉ុន្តែឱ្យតែគាត់កាន់ជក់គូររូបហើយ ក្នុងលោកនេះគ្មានអ្វីធំជាងរូបគំនូររបស់គាត់ទេ ។ សូម្បីខ្ញុំនេះ ក៏ដោយ ...

ឥរិយាបថរបស់គាត់ដូច្នេះ គឺជាការប្រមាថចំពោះខ្ញុំ, ជានារី ដែលសាហាវដូចពស់វែកនេះដែរ ។ ខ្ញុំបោះសំដីដ៏ក្តៅក្រហាយថា :

- នែ៎ ! លោកសិល្បៈករ, ខ្ញុំមិនអាចទ្រាំបាននឹងការសោះ អង្កើយរបស់លោកបានទេ ។ ខ្ញុំសូមសួរបញ្ជាក់លោកនៅពេលនេះថា តើលោកទៅឬមិនទៅជាមួយខ្ញុំ ?

បងវិចិត្រនៅស្ងៀមដដែលឥតកម្រើក ។ ខ្ញុំជូនសំណួរជាលើកទីពីរ ។ រួចជាលើកទីបី ...

ខ្ញុំបោះជំហានដើរចេញដោយសំដៅមាត់ទ្វារ, ទៅដល់មាត់ទ្វារ ខ្ញុំលាន់ក្បាលត្រមោង ហើយខ្ញុំបើកទ្វារ ក៏ប៉ុន្តែខ្ញុំងាកក្រោយដោយខ្ញុំ ដឹងច្បាស់ថាគ្រប់ៗគ្រាដែលខ្ញុំចេញទៅ បងវិចិត្រតែងតែងាកមុខមកញញឹមដាក់ខ្ញុំ ។ ប៉ុន្តែម្តងនេះខុសស្រឡះ បងវិចិត្រឥតងាកចេញ ពីផ្ទាំងគំនូររបស់គាត់ឡើយ ។ ខ្ញុំបើកទ្វារហើយខ្ញុំចេញពាក់កណ្តាលខ្លួនដោយបែរមុខមកខាងក្នុងផ្ទះ ។ បងវិចិត្ររក្សាឥរិយាដើមឥតកម្រើកដដែល ។ ខ្ញុំបិទទ្វារគ្រឹបហើយខ្ញុំចុះជណ្តើរ ។

នៅពេលដែលខ្ញុំដើរមកដល់ថ្នល់, កាលពីដើម, បងវិចិត្រឈរ មើលខ្ញុំតាមបង្អួច ។ ម្តងនេះបង្អួចឥតបើកសោះ ។ សេចក្តីក្តៅ ក្រហាយដែលខ្ញុំមានស្រាប់មកហើយនោះ ក៏ឆេះដង្គោលឡើងបីដូចជាអគ្គីភ័យ ។ ថ្វីរណោះម៉ោង៧យប់ទៅហើយ, គួរណាស់តែបង វិចិត្រយករថយន្តរបស់គាត់ជូនខ្ញុំទៅផ្ទះវិញ ។ ក៏ប៉ុន្តែបងវិចិត្រថ្ងៃ

នេះពុំដូចជាបងវិចិត្រកាលពីអាទិត្យមុននោះទេ ។ តើបងវិចិត្រលែងស្រឡាញ់ខ្ញុំឬ ? ឬមួយក៏បងវិចិត្ររវល់មែន ?

សេចក្ដីក្ដៅក្រហាយរបស់ខ្ញុំ ពុំអនុញ្ញាតឱ្យខ្ញុំគិតអ្វីក្រៅពីយក កំហឹងមកដាក់ក្នុងបេះដូងនោះឡើយ ។ ជាការពិតណាស់ថា ខ្ញុំជានារីមួយរូប ហើយកាលបើខ្ញុំប្រគល់កាយទៅឱ្យគេហើយ ជាការធម្មតាទេ, បុរសនោះត្រូវតែធុញទ្រាន់នឹងខ្ញុំ ។ ខ្ញុំជាចំពូកស្រីដែលទុំមុនស្រគាល ហើយខ្ញុំជាស្រីមួយរូបពុំចេះទប់ចំណង់នៃកាមតណ្ហារបស់ខ្ញុំបានឡើយ ។ ពិតហើយពាក្យសុភាសិតបារាំងមួយ ពោលថា "ស្រីនិយាយជាមួយបុរសទី១, លួចមើលបុរសទី២, ហើយនឹកគិតដល់ បុរសទី៣" "La femme Parle avec le premier home. regarde le deuxieme et pense au troirsieme"

ប៉ុន្តែនិយាយដោយត្រង់ទៅ, មុនពេលដែលខ្ញុំបានស្គាល់បង វិចិត្រ, ខ្ញុំដើរលេងខ្លះមែន ប៉ុន្តែពុំដែលហួសគន្លងប្រពៃណីម្ដងណាឡើយ ។ ហើយបុរសទី១នៃជីវិតរបស់ខ្ញុំដែលបានហែកហួរដួងចិត្ត ខ្ញុំនោះ គឺគ្មាននរណាក្រៅពីបងវិចិត្រនេះឡើយ ... តើបងវិចិត្រគេ ធុញទ្រាន់នឹងខ្ញុំមែនឬ ? គ្មានបញ្ហាអ្វីចោទ ឡើយចំពោះខ្ញុំជានារី មួយរូបដែលស្គាល់អារ្យធម៌ ។

# ២

# ក្ដីបារម្ភ

នៅពេលដែលវិចិត្រផាត់ពណ៌គំនូររបស់ខ្លួនរួចហើយ, អ្នកក៏ងាកក្រោយដើម្បីរកមើលសង្សារ ។ កន្ទ្រី បានចេញផុតទៅហើយ ? កាលពីមុនកន្ទ្រីធ្លាប់និយាយថា "អូនលាបងហើយ" ក៏ប៉ុន្តែកន្ទ្រីឥត ទៅណាសោះ កន្ទ្រីអង្គុយនៅឯសាឡុងខាងក្រៅរង់ចាំអ្នកដដែល ។ ម្ដងនេះកន្ទ្រីទៅមែន... អ្នកមានសេចក្ដីសោកស្ដាយណាស់ ដែលមិនបានជូននាងទៅ, ក៏ប៉ុន្តែអ្នកមានបំណង ចង់បង្ហើយផ្ទាំងគំនូរនេះដែរ ។ កាលណាថ្នាំស្ងួតគេពុំអាចបំផ្លែងពណ៌ទៅតាមបំណងបានឡើយ ។ សិល្បករ, ជាការធម្មតាទេ ដែលប្រពន្ធរបស់ខ្លួនផិតជានិច្ច សិល្បករ, គ្មានយកចិត្តទុកដាក់អ្វីខ្លាំងក្រៅអំពីសិល្បៈរបស់ខ្លួនទេ, ហើយគេ តែងឃើញសិល្បករជាច្រើន ដែលទទួលការអភ័ព្វណាស់ ក្នុងវិស័យស្នេហា ...

មែន ! មែន ! វិចិត្រពុំបានតាំងខ្លួនជាសិល្បកររហូតដល់ទៅ ភ្លេចបាយភ្លេចទឹក ហើយជាពិសេសគឺភ្លេចសង្សារកន្ទ្រីសម្លាញ់នោះ ឡើយ ... តើហេតុអ្វីបានជាអម្បាញ់មិញនេះអ្នកមានឬកពាច្រលើសបើសដាក់គេដូច្នេះ ? វិចិត្រក៏ពុំយល់ចំពោះខ្លួនឯងដែរ ។ មែន ! ចរិតលក្ខណៈមនុស្សមានពេលខ្លះគេពុំអាចពណ៌នា បានដូច្នោះមែន ។

អ្នកសង្ឃឹមច្បាស់ថា, បន្តិចទៀតកន្ទ្រីនឹងវិលត្រឡប់មករកអ្នកវិញ ហើយគេទាំងពីរនឹងបានក្រសាលតាមដងទន្លេ ឬតាមវិថីនានានៃទីក្រុង ។ កន្ទ្រីខឹងមិនយូរទេ .... ខឹងក៏មិនប្រវែងណាដែរ !

គិតទៅពេលវេលាកន្លង១ម៉ោងហើយ តែនាងឥតលេចស្រមោលមកវិញសោះ ។ ទីបំផុតអ្នកក៏ដើរទៅកាន់ទូរស័ព្ទហើយក៏វៃលេចផ្ទះរបស់កន្និរី ...

- អាឡូ ... កន្និរីឬ ? វិចិត្រសួរនៅពេលដែលឮដៃទូរស័ព្ទ ឯម្ខាង ឯណោះត្រូវគេលើកឡើង ។

សម្លេងក៏ឆ្ការមួយទៀតឆ្លើយតបមក, ដោយរីករាយដែរ:

- មិនមែនទេ , នរណាហ្នឹងសម្លេងដូចជាវិចិត្រមែនទេ ?

- ពិតហើយអ្នកបងរេខា ។ កន្និរីទៅដល់ផ្ទះហើយឬនៅបង ?

រេខាជាបងស្រីរបស់កន្និរី ។ នាងធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សាមួយក្នុងទីក្រុង ។ ដោយបានអប់រំនាងកន្និរីតាំងពីតូចមក ។ កន្និរីនេះមានការកោតគោរពបងស្រីដូចជាម្តាយ ពីព្រោះអ្នកទាំងពីរ នេះកំព្រាឪពុកម្តាយតាំងពីក្មេងដូចគ្នា ។

- វិចិត្រ កន្និរីមកដល់ផ្ទះមួយភ្លែត ហើយស្រាប់តែប្រាប់ខ្ញុំថា "អ្នក បង ! ខ្ញុំសុំទៅមើលកុនហើយ !" ថាប៉ុណ្ណេះកន្និរីក៏ចេញទៅ ។

- ម៉េចក៏អ្នកបងបណ្តោយឱ្យកន្និរីទៅតែម្នាក់ឯងដូច្នោះ ?

- ព្រោះខ្ញុំកំពុងកែកិច្ចការកូនសិស្ស ។ កន្និរីប្រហែលជា ធុញទ្រាន់គ្មាននរណានិយាយជាមួយក៏មិនដឹងស្រាប់តែទៅបាត់ដោយខ្ញុំមិនទាំងបានដឹងខ្លួនផង ។ ខ្ញុំទើបតែដឹងអម្បាញ់មិញនេះ !

- ទៅមើលកុននៅរោងណាបង ?

- នាងប្រាប់ខ្ញុំថាទៅមើលរឿងនៅឯរោងកុនបូកគោ ...

ទីបំផុតការសន្ទនាតាមទូរស័ព្ទនេះក៏ចប់ ។ វិចិត្ររេរាក្នុងចិត្តបន្តិច ។ ការទៅរកមនុស្សម្នាក់នៅក្នុងរោងកុនពុំមែនជាការងាយស្រួលនោះទេ, ដូច្នេះអ្នកត្រូវតែស្ថិតនៅក្នុងផ្ទះរបស់អ្នកដើម្បីធ្វើការបណ្តើរនិងរង់ចាំបណ្តើរ ។ តែពីរម៉ោងប៉ុណ្ណោះ

ភាពយន្ត នឹងចប់ ហើយដប់នាទីប៉ុណ្ណោះ, កន្និរីនឹងមកដល់ផ្ទះគឺនៅម៉ោង៩និង១០នាទី, អ្នកនឹងរវៃទូរស័ព្ទទៅជាថ្មីម្តងទៀត ...

វិចិត្របាក់ដឹងថា អ្នកដូចជាមានចិត្តធឹងធោងជាខ្លាំង នៅពីមុខ ផ្ទាំងគំនូរថ្មីមួយទៀតដែលអ្នកទើបតែចាប់ផ្តើមផាត់ពណ៌នេះ ។

ពេលវេលាកន្លងទៅរហូតដល់ម៉ោង ៩និង១៥នាទី, រួចម៉ោង ៩កន្លះ ។ វិចិត្រក៏លើកទូរស័ព្ទរវៃលេខជាថ្មីឡើង ដើម្បីហៅកន្និរី នៅគេហដ្ឋានរបស់នាង ទីបំផុតគឺសម្លេងរបស់រេខាទេដែលនិយាយមកថា

- កន្និរីមិនទាន់មកដល់ផ្ទះវិញសោះ, វិចិត្រ, ខ្ញុំឆ្ងល់ណាស់ហេតុ អ្វីក៏យូរដូច្នេះ ?

៣

## អន្ទាក់ចៃដន្យ

ពីរម៉ោងនៅក្នុងការទស្សនាខ្សែភាពយន្ត ផ្នែកសោកនាដកម្មនេះ កាន់តែបណ្ដោយឱ្យខ្ញុំមានសេចក្ដីក្ដៅក្រហាយថែមទៀតចំពោះបុរស ខ្ញុំជាស្រីដែល កំពុងតែមានគំនុំគុំគួនស្រាប់ផងនោះ ឥឡូវមកមើល ប៉ះរឿងមួយដែលជារឿងសោកនាដកម្មដ៏សែនឈឺចាប់ ។ នៅពេល ចេញពីរោងភាពយន្ត, ខ្ញុំគេចខ្លួនទៅឈរនៅជ្រុងម្ខាង ហើយខ្ញុំងើយ មើលទៅលើមេឃ ព្រះច័ន្ទរះក្រឡង់នៅកណ្ដាលហ្វូងតារា, ខ្យល់បក់ល្វើយៗ ។

ស្រាប់តែមិនដឹងចៃដន្យអ្វី, អារម្មណ៍របស់ខ្ញុំបានញ៉ាំងចិត្តខ្ញុំ ឱ្យចង់ដើរ ។ លំនៅស្ថានរបស់បងស្រីខ្ញុំស្ថិតនៅវិថីប្រជាធិបតេយ្យហើយពុំសូវជាឆ្ងាយពីទីនេះប៉ុន្មានទេ មនុស្សម្នាក៏នៅតែមានធ្វើដំ ណើរគោចរទៅវិញទៅមកទាំងស្រីទាំងប្រុសហូរហែរដែរ ។ ខ្ញុំឈរ នៅឯជ្រុងងងឹតបន្តិចដោយចិត្តមួរហ្មង, ហើយហាក់ដូនជាពុំទាន់មាន បំណងចង់ទៅផ្ទះវិញភ្លាមៗទេ ។ កំហឹងរបស់ខ្ញុំឆេះឆួលយូរណាស់ ។ តែប៉ុន្មាននាទីក្រោយមក មនុស្សម្នាវិលទៅលំនៅស្ថានស្ងាត់អស់, ខ្ញុំ ក៏បោះជំហានចេញមក ។ ក្នុងមួយខណៈនោះ, ខ្ញុំឮសម្រែកមួយ, ហើយខ្ញុំក៏ងាកក្រោយ ។ តើខ្ញុំឃើញទស្សនីភាពអ្វី ? គឺស្ត្រីចាស់ ម្នាក់ដែលដួលហើយខ្ញុំឃើញតាចាស់ជាប្ដី កំពុងតែស្ទុះទាំងទទីទទាជួយលើកភរិយារបស់ខ្លួន ។ តាំងពីដើមរៀងមក, ខ្ញុំជានារីមានពូជ អម្បូរ ហើយតែងតែយកចិត្តទុកដាក់ការជួយអ្នកដទៃជានិច្ច ។

ឃើញស្ត្រីចំណាស់មួយរូបដែលដួលដោយភ្លាត់ជើងដូច្នេះ, ខ្ញុំក៏ស្ទុះទៅ ជួយគ្រាហ៍ជា

មួយតាចាស់នោះ ។ ស្ត្រីចាស់ក៏ក្រោកឈរឡើង, ចំ ណែកតាចាស់ជាប្តីក៏មានការស្រយុតស្រយង់ជាខ្លាំង ។ ខ្ញុំឃើញបបូរមាត់គាត់ញ័រៗ ភ្នែករបស់គាត់បិទបើកម៉ក់ៗ ។

- ម៉េចយាយប៉ិតឈើចាប់អ្វីទេឬ ?

ស្ត្រីចំណាស់នេះដកដង្ហើមបន្តិច ហើយក៏និយាយក្នុងភាពងងឹត នៅមុខរោងភាពយន្តដែលគេទើបនឹងបិទភ្លើងនេះ ដោយពាក្យមួយៗ ថា

- ខ្ញុំមិនបានដឹងដែរ, មិនដឹងជាវាឈឺចាប់ឬគ្រេចត្រង់ណាឡើយ ...

ស្ត្រីចំណាស់នេះបោះជំហានទៅមុខហើយស្រាប់តែទ្រេតចង់ដួល រួចទ្រេតខ្លួនមកកាន់ស្មាខ្ញុំដើម្បីទប់ ។

- ឱព្រះអើយ ! ស្ត្រីចំណាស់នេះស្រែកឡើង ។

ខ្ញុំគ្រេចកជើងហើយ ។ អៃយ៉ូយឈឺម្លេះ !

តាចាស់ក៏មកជួយគ្រាហ៍ភរិយាខ្លួននៅម្ខាង, ហើយដោយឃើញភាព ទទ្រេតទទ្រោតដូច្នេះ ខ្ញុំក៏មិនទាន់លះបង់តាចាស់យាយចាស់ ដែលមានភាពដូចឪពុកម្តាយខ្ញុំនេះទេ ។ ម្យ៉ាងទៀតខ្ញុំពុំដែលរស់នៅ ក្រោមសេចក្តីថ្នាក់ថ្នម របស់មនុស្សចាស់ណាម្នាក់ទាល់តែសោះ ។ ការដែលបានជួយស្រោចស្រង់គេ មួយរយៈកាលដូច្នេះបណ្តាលឱ្យទឹកចិត្តខ្ញុំរីករាយ ហើយជំនោរនៃសេចក្តីល្អ របស់ខ្ញុំមិនទាន់ធ្លាក់មក សណ្ឋិតទៀតនៅឡើយទេ ។ ខ្ញុំក៏និយាយឡើងថា :

- អ៊ំស្រីអញ្ជើញកាន់ដៃខ្ញុំមក ខ្ញុំនឹងជួយទប់អ៊ំស្រី ហើយបន្តិចទៀត ស៊ីក្លូមកដល់អ៊ំស្រីអាចអញ្ជើញបាន ។

- ទេ, ទេ, ទេ តាចាស់និយាយ , យើងមានឡានមួយនៅមិន ឆ្ងាយពីទីនេះប៉ុន្មាននេះនឹ ! តាចាស់ជាប្តីចង្អុលទៅឡានខ្មៅយង់មួយ ដែលចតនៅពីក្រោមដើមឈើ ។ បន្ទាប់មកស្រីចំណាស់នេះក៏និយាយ យ៉ាងទន់ភ្លន់ថា :

- ក្មួយស្រី, ក្មួយស្រីអាចទៅជាមួយអ៊ំបាន ។ អ៊ំទាំងពីរនឹងជូន ក្មួយស្រីទៅដល់ផ្ទះ ។ ប៉ុន្តែអ៊ំសុំពឹងក្មួយបន្តិចគឺថា ក្មួយស្រីត្រូវទៅ ផ្ទះអ៊ំមួយភ្លែតសិន ដោយគ្រាន់តែជួយគ្រាហ៍អ៊ំឱ្យចុះពីឡាននិងចូលក្នុងផ្ទះប៉ុណ្ណោះ ។ បន្ទាប់ពីនេះ អ៊ំប្រុសអាចនឹងបើកឡាននេះជូនក្មួយ ត្រឡប់ទៅផ្ទះវិញភ្លាម ។ តែ ៥ឬ៧នាទីប៉ុណ្ណោះ ។ អ៊ំមានតែប្តី ប្រពន្ធពីរនាក់ប៉ុណ្ណោះ ។

តើមានអ្វីជាឧបសគ្គចំពោះរូបខ្ញុំ ក្នុងការជួយគ្រាហ៍ស្ត្រីម្នាក់នេះ ហើយដែលប្តីរបស់គាត់ក៏ចាស់ដែរ ពុំអាចបំពេញភារកិច្ចនេះបានតែម្នាក់ឯង ? ការជួយអ្នកដទៃមួយភ្លែត រួចត្រឡប់មកផ្ទះវិញក៏ឈ្មោះ ថាសប្បុរសធម៌មួយដែរ ។ ណាមួយ ខ្ញុំចង់ធ្វើអំពើមួយដើម្បីបំភ្លេច សេចក្តីឈឺចាប់របស់ខ្ញុំចំពោះបងវិចិត្រទៀតផង ។ ខ្ញុំក៏ឡើងរថយន្តនេះ ។ គឺជារថយន្ត CITROEN ពណ៌ខ្មៅ ។ ក្នុងពេលដែលម៉ាស៊ីនវា ឆេះ រថយន្តនេះក៏ញ័រអស់ទាំងតួ ។ រថយន្តក៏ចេញទៅ ...

ខ្យល់ផាត់ចូលតាមទ្វាររថយន្ត, ត្រជាក់ស្រឹតដល់ដួងគម៌ល ក្នុងមួយរំពេចនោះស្រាប់តែខ្ញុំភ្ញាក់ខ្លួនឡើង ហាក់បីដូចជាភ្ញាក់ពីស្ថានសុបិនដូច្នោះ ... យី ! តើខ្ញុំទៅណា ? ប៉ុន្តែពេលនេះជ្រុលហួសហើយ, រថយន្តកំពុងតែបោលទៅមុខ ។ តាមរស្មីអគ្គិសនីដែល ជះពីដងគោមមកម្តង១ នោះដោយចៃដន្យ, ខ្ញុំចោលភ្នែកមើលទៅ អ្នកបើកបររថយន្ត ។ គាត់នេះប្រកាន់ឥរិយាបថស្ងៀមហើយហាក់ ដូចជាឥតគិតគូរអ្វីក្រៅតែពីមើលផ្លូវនោះឡើយ ។ នេត្ររបស់ខ្ញុំ គាប់ជួនប្រទះលើដៃរបស់គាត់ទាំងពីរ ដែលកំពុងកាន់ចង្កូតរថយន្ត ។ វេទនារម្មណ៍មួយក៏ផ្ទុះឡើង ដែលធ្វើឱ្យខ្ញុំរញ្ជួយអស់ទាំងកាយា។ ក៏ប៉ុន្តែជ្រុលពេលទៅហើយ, រថយន្តកំពុងតែបោលទៅមុខ ... រថយន្តបត់បែនជាច្រើន កន្លែងហើយខ្ញុំហាក់ដូចជាវង្វេងអស់ពុំដឹងថា ទីណាទៀតផង,

ផ្លូវស្ងប់ស្ងាត់ហើយវែងសន្ធឹងទៅមុខលន្លង់លន្លោច ។ ក៏ប៉ុន្តែទោះបីយ៉ាងណាក្តី ខ្ញុំនៅតែជឿថានេះជាក្រុងភ្នំពេញ ព្រោះយានរត់មិនទាន់បានដប់នាទីផងទេ ...

ក្នុងពេលនោះស្នូរក្រដាសទម្ពិចក្តាយ៉ាងស្ងួត រួចខ្ញុំបែរទៅស្ត្រីចាស់ ។ ស្ត្រីចំណាស់ ក៏និយាយដោយទន់ភ្លន់ថា

- ក្មួយស្រី ខ្ញុំបានទិញគ្រាប់ស្ករនេះកាលពីថ្ងៃ ។ ក្មួយស្រីក៏ដឹងដែរថា មនុស្សចំណាស់ខ្ញុំទាំងប្តីខ្ញុំទាំងរូបខ្ញុំ បែរទៅជាមានបំណងចង់បរិភោគស្ករ ដូចកាលដែលយើងនៅយុវវ័យដូចក្មួយស្រីដូច្នោះឬ !

ខ្ញុំស្រឡាញ់ណាស់ស្ករនេះ ។ ម្យ៉ាងទៀតខ្ញុំហាក់ដូចជា មានការរំជើបរំជួលជាខ្លាំង តាំងពីល្ងាចមិញម្ល៉េះបន្ទាប់ពីមានរឿង រ៉ាវជាមួយបងវិចិត្រមក ។ គ្រាប់ស្ករគឺឱសថម្យ៉ាងសំរាប់រម្ងាប់ការ រញ្ជួយចិត្តដូចជាពេលឡើងជិះយន្តហោះ, គេតែងតែចែកស្ករនេះដល់អ្នកដំណើរ ។ រំលឹកឃើញរឿងនេះខ្ញុំក៏ ទទួលគ្រាប់ស្ករពីស្ត្រីចំណាស់ដោយឥតរារែកឡើយ ។ ស្ត្រីចាសក៏រលាស់សំណួរថា :

- ក្មួយស្រីនៅឆ្ងាយពីទីនេះមែនទេ ? តែម្នាក់ឯងមែនទេ ?

- ទេ, ខ្ញុំនៅមិនឆ្ងាយពីរោងកុនបូកគោប៉ុន្មានទេ, ខ្ញុំរស់នៅជា មួយបងស្រីខ្ញុំជាគ្រូបង្រៀនម្នាក់, អ៊ំស្រី, មិនយូរប៉ុន្មានទេប្រហែល ជាខែក្រោយនេះខ្ញុំនឹងរៀបការជាមួយបងវិចិត្រ ។

ក្នុងភាពងងឹតព្រិល១ នៃរថយន្ត, ខ្ញុំឃើញនេត្រាស្ត្រីនេះសម្តែង សេចក្តីរីករាយ ។ ក្នុងមួយរំពេច, ខ្ញុំហាក់ដូចជាភ្លេចអ្វី១ទាំងអស់ ហើយខ្ញុំបានឮស្ត្រីចំណាស់និយាយកម្សាចិត្តខ្ញុំថា :

ជាការប្រសើរណាស់ ដែលគេប្រព្រឹត្តយុវវ័យឱ្យកន្លង ទៅនៅក្នុងក្របខ័ណ្ឌប្រពៃណី ! យុវជននិងយុវនារីនាសម័យនេះ, ពុំសូវបានស្គាល់អត្ថន័យ ជាក់ច្បាស់អំពី

ទំនៀមទំលាប់នេះទេ ... ភាគច្រើនសុទ្ធតែជ្រុលខ្លួន, មិនថាអ៊ីចឹងតាប៉ិ ? កាលជំនាន់យើងពី ដើមម្តាយឪពុកចាប់គ្នារៀបមង្គលការមានអី គេចេះតែស្រឡាញ់គ្នាដូច្នោះទៅកើតដែរ ! ប៉ុន្តែយុវជនសម័យនេះពុំអាចធ្វើជាគ្រឿង ឧបករណ៍នៃស្នេហាបានទេ ។ ប៉ុន្តែការដែលជួបគ្នាក្នុងប្រពៃណី ទំនៀមទំលាប់គឺជាការមួយគួរឱ្យសរសើរណាស់, មិនថាអ៊ីចឹង ?

ខ្ញុំអរព្រួចក្នុងចិត្ត ហើយផ្អែកទៅលើបង្អែកនៃរថយន្ត ។ ស្ត្រីចាស់បន្ថែមសំដីថា

- តែ ៣-៤ នាទីទៀតទេក្មួយស្រី , ក្មួយស្រីនឹងបានត្រឡប់ទៅ ផ្ទះវិញហើយ ...

ខ្ញុំភ្ញាក់ស្រឡាំងកាំងដោយរថយន្តឈប់ភ្លាម ។ ខ្ញុំទើបតែនឹងដឹង ថារថយន្តនេះបានចូលមកក្នុងផ្លូវមួយមានភ្លើងបំភ្លឺព្រឿងៗ ប៉ុណ្ណោះ ,ដោយសារ ចង្កៀងគោមជំនាន់បុរាណមួយដែលបញ្ឈរនៅឯជញ្ជាំង ។ នៅពីខាងក្រោយខ្ញុំ គឺជាផ្លូវចាក់កៅស៊ូមួយហើយដែលខ្ញុំពុំដឹងថា ផ្លូវនោះឈ្មោះផ្លូវអ្វីផង ។ ទីនេះគឺជាច្រកដែលបន្តពីផ្លូវធំមក ហើយមក ទាល់ត្រង់របងចម្រឹងដែកដ៏ស្រួចហើយខ្ពស់នៃវិមានមួយ ។ ទីនេះងងឹត, តាចាស់ក៏ចុះពីរថយន្តរួចដកកូនសោរពីហោប៉ៅ ហើយបើកទ្វារចម្រឹងដែក រួចត្រឡប់មកកាន់រថយន្តវិញ ។

ខ្ញុំបែរក្បាលទៅក្រោយ ដើម្បីមើលវិថីចាក់កៅស៊ូ នោះម្តងទៀត, ក៏ប៉ុន្តែករបស់ខ្ញុំហាក់ដូចជារឹង, តើកើតហេតុអ្វី ? រួចត្រចៀករបស់ខ្ញុំហាក់ដូចជាហ៊ឹង, ហើយខ្ញុំឮសូរសម្លេងល្វើយ ៗ

- ក្មួយស្រីអញ្ជើញចុះ !

- ចា៎ះ, អ៊ំស្រី, ខ្ញុំឆ្លើយតបទៅហេវហត់ជាខ្លាំង ។

តើខ្ញុំកើតអ្វីក្នុងខ្លួនខ្ញុំ ដែលកាលពីដប់នាទីមុននេះ ខ្ញុំមានសុខភាពពេញខ្លួនទាំងអស់ ? ទ្វារឡានចំហរដោយតាចាស់ ខ្ញុំហាក់ដូច ជាពុំដឹងថាខ្ញុំដាក់ជើងលើដីទៀតផង ។ ខ្ញុំងើយក្បាលឡើងលើ ដើម្បីស្រូបយកដង្ហើមថ្មីនាពេលរាត្រី ។

នៅពេលដែលខ្ញុំឈរ , ស្រាប់តែមួយរំពេចនោះខ្ញុំដួលប្រូសទៅលើដី ។ យីហេតុអ្វីដូច្នេះ ? នៅជុំវិញខ្លួនខ្ញុំអ្វីៗ វិញខ្វាល់ទាំងអស់ ។

នៅពេលដែលតាចាស់ ជួយគ្រាហ៏ខ្ញុំក្រោកឈរឡើងនោះ, ក្នុងពេលនោះ, ឯងខ្ញុំឮសូរសម្លេងរថយន្តមួយបើកបរនៅឯផ្លូវចាក់កៅស៊ូខាងក្រៅខ្ទងខ្ញុំ ។ បេះដូងរបស់ខ្ញុំរំជើបរំជួលយ៉ាងចម្លែកបំផុត ។ បងវិចិត្រ ! សូររថយន្ត នេះទោះបីជាបន្លឺនៅក្នុងចំណោម រថយន្ត ១000 ទៀតក៏ខ្ញុំឥតច្រលំដែរ ! សេចក្តីនឹករឮកដល់រឿងចាស់ , ដល់រឿងស្នេហារបស់ខ្ញុំក៏លុកទន្រ្ទានក្នុងដួងចិត្តថា "បងវិចិត្រ ប្រហែលជាបើករថយន្តតាមរកខ្ញុំ ។ ខ្ញុំបង្ហើយកិច្ចការឥឡូវ ខ្ញុំនឹងបានត្រឡប់ទៅផ្ទះវិញហើយ ..."

បង្ហើយកិច្ចការស្អី ? ខួរក្បាលរបស់ខ្ញុំចាប់ផ្តើមវិលជាថ្មី ហើយ ខ្លាំងជាងមុនទៀតផង ។ ខ្ញុំលែងគិតឃើញក្នុងការជួយសង្គ្រោះអ្នកណាទាំងអស់, យាយចាស់តោងស្មារប្តីគាត់ដើរប៉ាច់ពៀចៗ ទំនងជាគ្រេចភ្នែកគោលមែន ។

ក៏ប៉ុន្តែក្នុងពេលជាមួយគ្នានោះ ខ្ញុំឮសម្លេងដែលស្រ្តីនិយាយ ហាក់បីដូចជាឆ្ងាយល្ងើយអើយសែនល្ងើយ :

- ស្រេចហើយបង ... នាងស្រីនេះធន់បានយូរណាស់ ...

អាថិកំបាំងក៏បើកឡើងភ្លាមមួយរំពេច ។ សេចក្តីតក់ស្លុតមួយ ដែលពុំអាចទ្រាំទ្របានចូលមកច្របាច់បេះដូងខ្ញុំ ។ ភ្លាមមួយរំពេច នោះឯងខ្ញុំបាត់បង់អស់ក្នុងឋានៈខ្ញុំជាម្ចាស់នៃចលនានៃរាងកាយខ្ញុំ ។ ខ្ញុំដឹងច្បាស់ណាស់ថាខ្ញុំត្រូវគេដាក់ថ្នាំសណ្តំ ។ ដោយខ្ញុំធ្លាប់អានប្រលោមលោកផ្នែកខាងប៉ូលិសនិងចារកម្ម ជាច្រើនខ្ញុំក៏នឹក

ឃើញថា "នេះជាកលល្បិចជំនាន់បូរាណ។ គេសុំឱ្យស្ត្រីម្នាក់ជួយគេពីរឿងអ្វី មួយដែលខានពុំបាន ហើយគេក៏អញ្ជើញនាងឱ្យទទួលការជិះរថយន្ត របស់គេរួចគេផ្តល់ទឹកភេសជ្ជៈឬគ្រាប់ស្ករតាមការគួរ ។ បន្ទាប់មក នាងក៏ប្រគល់ខ្លួនទៅឱ្យសត្រូវរបស់នាងដោយឥតមានអ្វីការពារខ្លួនសោះឡើយ ..."

ប៉ុន្តែទោះបីយ៉ាងនេះក្តី ខ្ញុំហាក់ដឹងថាខ្ញុំកំពុងតែបោះជំហានដើរ ម្តងនេះពុំមែនខ្ញុំទេដែលគ្រាហ៍យាយចាស់, គឺយាយចាស់ឯណោះទេ ដែលគ្រាហ៍ខ្ញុំវិញ ។ មែនខ្ញុំទើបតែនឹកឃើញថា ក្នុងពេលដែល រថយន្តកំពុងរត់តាមដងវិថីនោះ ដោយបន្លឺចង្កៀងអគ្គិសនីជះមកម្តងៗនោះខ្ញុំរំលឹកឃើញថា ខ្ញុំបានឃើញដៃរបស់តាចាស់អ្នកបើកបរ មែនខ្ញុំបានពិនិត្យឃើញថា គឺជាដៃរបស់បុរសនៅក្មេងនៅឡើយ !

ដោយខ្ញុំបានដឹងរឿងអកុសលរបៀបនេះ តាមប្រលោមលោក ផ្នែកប៉ូលិសនិងចារកម្មជាច្រើនរឿង, ខ្ញុំខំយកជំនះខាងផ្លូវចិត្តរបស់ ខ្ញុំ កុំឱ្យទ្រុឌទ្រោមទៅតាមអនុភាពនៃថ្នាំ ។ ខ្ញុំបង្កើនសេចក្តីក្លាហាន ថ្វីត្បិតតែកម្លាំងរបស់ខ្ញុំកាន់តែទ្រុឌទ្រោមទៅៗក៏ដោយ ។ ខ្ញុំមិនបើកភ្នែកទេ ក៏ប៉ុន្តែខ្ញុំដឹងនូវអ្វីៗទាំងអស់ដែលកើតឡើងជុំវិញខ្ញុំ ។ បុរសស្ត្រីក៏នាំខ្ញុំចូលក្នុងផ្ទះពេលនេះ ។ ខ្ញុំគ្មានសមត្ថភាពដើម្បីរត់ទៅឡើយ ... ខ្ញុំមានតែព្រេងសំណាងតែម្យ៉ាងប៉ុណ្ណោះ, ព្រេងសំណាងម្យ៉ាងប៉ុណ្ណោះ ...

ខ្ញុំឮសម្លេងល្វើយៗ ដែលគេពោលមកកាន់ខ្ញុំ :

- ម្តងនេះស្រេចហើយ, នាងលែងធន់បាននឹងកម្លាំងថ្នាំនេះ ហើយ ...

- ស្រីនេះស្អាតណាស់, សម្លេងបុរសអ្នកបើកឆ្លើយតប ។ ស្អាតម្ល៉េះព្រះអើយ ... ខ្ញុំកម្ររកឃើញស្រីដែលមានសោភ័ណភាព ដូច្នេះណាស់ ។ នាងនេះមានកាយដូចទេវនារី, នេត្រាភ្លឺថ្លា រោម ចិញ្ចើមក្រាស់, រោមភ្នែករវែង, សាច់ម៉ដ្ឋខៃ,

សុដនមានជ្រលងល្អល្អះ ពេកកន្លង, រាងកាយរបស់នាងមានសភាពល្វត់ល្វៃឥតបើថ្លែងបាន ...

ឱព្រះអើយ តើ ? តើបុប្ផសំខាន់របស់នាង មានរស់ជាតិប៉ុណ្ណាទៅ ? បបូរមាត់របស់នាងមានសភាពស្រស់ញញឹមជានិច្ច បីដូចជាស្រទាប់ ផ្កា ... ក្លៀករបស់នាងមានសភាពគួរឱ្យចង់ក្លែម, ដែលពោរពេញ ទៅដោយព្រៃស្រោង ...

បានហើយបងផ្លេក, ដោយសារមីចាបញីដែលនៅក្រពុំដូច ក្រពើញីឡើងខ្លួននេះ យើងនឹងបានរង្វាន់ជាច្រើន ហើយយើងរស់អស់កាលដ៏យូរ ប្រហែលជាយើងលែងប្រព្រឹត្តអំពើទុច្ចរិតទៀតហើយក៏មិនដឹង !

ស្ត្រីនិងបុរសនេះក៏គ្រាហ៍ខ្ញុំចូលទៅក្នុងបន្ទប់មួយ រួចក៏ចេញតាម ទ្វារក្រោយ ហើយក៏ឡើងជណ្តើរ ។ ទោះបីទ្រុឌទ្រោមខាងផ្លូវកាយក៏ដោយ, ទោះបីជើងខ្ញុំគ្មានកម្លាំងនឹងបោះជំហានទៅមុខក្តី, ក៏ប៉ុន្តែខ្ញុំនៅចងចាំជានិច្ច "ខ្ញុំត្រូវគិត, ខ្ញុំត្រូវតែគិត, ខ្ញុំមិនត្រូវដេកទេ, ខ្ញុំមិនត្រូវដេកទេ, បើមិនដូច្នោះទេ ខ្ញុំនឹងវិនាសហើយ, ហើយគ្មាននរណាមករកខ្ញុំឃើញនៅទីនេះទេ !"

ខ្ញុំដឹងថា គេគ្រាហ៍ខ្ញុំឱ្យឡើងលើជណ្តើ ដែលមាន១៥កាំ ដោយ ខ្ញុំរាប់ស្នូរណ្តើ នៃជំហានជើង ។ តើខ្ញុំនៅទីណា ឱព្រះពុទ្ធជាម្ចាស់អើយ !

ខ្ញុំឮសូរគេបើកទ្វារមួយ ។ គឺជាបន្ទប់ ។ ហើយក្នុងពេលជាមួយគ្នានោះ ខ្ញុំនឹកក្នុងចិត្តថា "ឱហ្ន៎, ប្រសិនបើខ្ញុំអាចក្អួតបាន, ពេលនេះ ប្រហែលជាខ្ញុំនឹងមានផ្លូវដោះខ្លួនបាន ។ គេអូសខ្ញុំទៅមុខជាថ្មី រួចគេលើកឡើងដាក់ទៅលើអ្វីមួយដែលខ្ញុំដឹងថា មានភាពទន់ត្រជាក់, គឺ ជាពូក ។ មួយរំពេចនោះខ្ញុំឮសូរក្រើក ! ... គឺការបើកគន្លឹះភ្លើង អគ្គិសនី, ដែលមានពន្លឺជះមកលើត្របកភ្នែកខ្ញុំ ។ ខ្ញុំខំទប់អារម្មណ៍ របស់ខ្ញុំមិនឱ្យគេស្គាល់ទឹកមុខ ដែលឥតសន្លប់របស់ខ្ញុំឡើយ, ហើយខ្ញុំ ខំទប់រាងកាយរបស់ខ្ញុំកុំឱ្យកម្រើក ។

តាមពិតខ្ញុំធ្លាប់ត្រូវគេដាក់ថ្នាំសណ្ដំម្ដង, ក្នុងពេលដែលខ្ញុំ ត្រូវទទួលការវះកាត់ខ្នែងពោះវៀននៅមន្ទីរពេទ្យ ។

ខ្ញុំបានឮការសន្ទនានៃអ្នកពង្រត់ខ្ញុំមក :

- ម៉ោងប៉ុន្មានហើយបងផ្លេក ? បងឯងឥតបានរៀបចំឡាន ពេទ្យទេ, មែនទេ ?

- ម៉ោង១១ហើយ "អាស្រី" ... អ្នកណាទៅដឹងមុននឹងបាន រៀបចំឡានពេទ្យ ? នេះគឺជាសំណាងមួយដែលយើងឥតបានព្រាង ទុកទេតើ , ហើយការទៅមើលកុនរបស់យើងវាហុចផលប្រយោជន៍មកដល់យើង, មិនថាអ៊ិចឹង ?

បើអ៊ិចឹងបងផ្លេកឯងត្រូវចាត់ការឱ្យបានស្រួលបន្តិចហើយ យើងត្រូវសម្រួលដើងការណ៍ ពីព្រោះគ្រួសាររបស់ស្រីនេះ, អាចនឹង ទៅប្ដឹងក្រសួងមានសមត្ថកិច្ច, ហើយប្រយ័ត្នតែមានភ្នាក់ងារណា ម្នាក់ដែលគេកត់លេខរថយន្តយើងបាន ... ប៉ៃ ! មិនមែនរឿង ស្រួលទេណា ! យើងត្រូវលៃយ៉ាងម៉េច ចេញឱ្យផុតពីទីនេះនៅម៉ោង ១២ កន្លះ ។ ទៅយើងបិទភ្លើងទៅ ...

ស្នូរបិទកុងតាក់ភ្លើងនៅក្បែរខ្ញុំ, ហើយសម្លេងឆ្លើយឆ្លងគ្នាក៏ឮ សូរល្វើយទៅៗ ក្រោយពីគេបិទទ្វារបន្ទប់ដែលខ្ញុំនៅហើយ ។

៤

# វិមាននរក

ខ្ញុំបើកភ្នែកភ្លាមក្នុងភាពងងឹតនៃរាត្រីចាក់ភ្នែកពុំយល់នេះ។ ខ្ញុំផ្ទៀងសោតាស្តាប់ ដោយសេចក្តីភ័យញ័ររន្ធត់នៅក្នុងសេចក្តីសង្ឃឹម មួយដ៏ឆ្កួតលីលា។ បន្តិចក្រោយខ្ញុំឮសូរទ្វារដែលនៅឯខាងក្រៅឯណោះរណ្តំ, ដែលធ្វើឱ្យខ្ញុំធូរទ្រូងសម្បើម រួចបន្ទាប់មកស្នូររោទិ៍នៃ រថយន្ត ដែលបើកចេញទៅ ។

ខ្ញុំត្រឡប់ក្បាលលើខ្នើយ ហើយចលនាដ៏សែនខ្សោយនេះផ្តល់ សេចក្តីសង្ឃឹមចំពោះខ្ញុំ ខទីមួយដោយសារវិមាននេះស្ងាត់ ហើយខ ទី២ដោយសារទីនេះគ្មានមនុស្សនៅទៀតផង ។ ការងងុយកំពុងតែ លុកទន្រ្ទានខ្ញុំខ្លាំងណាស់ ខ្ញុំយកជ័យជំនះលើឆន្ទះនេះទាល់តែបាន ។ ដំបូងបង្អស់ខ្ញុំត្រូវរិះរកមធ្យោបាយដើម្បីបើកភ្លើង ។ ពេលវេលាដែលនៅសល់សំរាប់ខ្ញុំខ្លីសែនខ្លី ។ ទីបំផុតខ្ញុំរាវទៅក៏ប៉ះនឹងចង្កៀង ដែលគេដាក់លើតុសំរាប់បំភ្លឺនៅពេលដេក ។ ខ្ញុំខំប្រឹងយកដៃទាញ គន្លឹះវាយ៉ាងអស់ទំហឹង ។ តាមពិតដៃខ្ញុំស្ទើរតែគ្មានកម្លាំងអ្វីបន្តិចសោះ។

ក៏ប៉ុន្តែសេចក្តីតក់ស្លុតអាចធ្វើឱ្យខ្ញុំខំប្រឹងក្រោកអង្គុយបាន ។ ខ្ញុំសាកល្បងបោះជំហានម្តងមួយៗ ដោយយកដៃទប់គ្រែផង ។ បន្ទប់ទឹកទៅពីមុខនេះ ។ គឺជាសេចក្តីសង្ឃឹមរបស់ខ្ញុំមួយដូចដែលអ្នក ស្រេកទឹកដើរកណ្តាល សមុទ្រខ្សាច់សាហារាបានជួបអណ្តូងទឹកមួយដូច្នោះ។ ខ្ញុំមិនមែនត្រូវការផឹកទឹកទេ, ផ្ទុយទៅវិញខ្ញុំត្រូវការក្អួត, គឺក្អួតដើម្បីបញ្ចេញ ភាពពិសពុលនេះឱ្យអស់ ។ ជើងដ៏ទ្រុឌទ្រោម ដោយអនុភាពថ្នាំរបស់ខ្ញុំពុំអាចទប់រាងកាយខ្ញុំបានឡើយ, ហើយទី បំផុតខ្ញុំក៏លុតជង្គង់ចុះយ៉ាងយឺតៗ ដោយជង្គង

ដ៏មាំនេះ ខ្ញុំកកិលបន្តិចម្តងៗ សំដៅទៅទ្វារបន្ទប់ទឹក ហើយលើកដៃកាន់ត្រមោងទ្វារ ធ្វើ ពីស្ពាន់បាន ។ ការខំប្រឹងជាចុងក្រោយបំផុត, ខ្ញុំក៏បើកទ្វារបន្ទប់ទឹកនេះបាន ។

គឺជាបន្ទប់ទឹកមួយដែលមានប្រដាប់ប្រើប្រាស់ គ្រប់គ្រាន់តាម សេចក្តីប៉ង ប្រាថ្នារបស់ខ្ញុំ ។ បង្គន់មួយនៅទីនោះ ខ្ញុំយកដៃលូកទៅក្នុងបំពង់ករបស់ខ្ញុំ ហើយខ្ញុំ ខំប្រឹងក្អួត, ទីបំផុតខ្ញុំក៏បានសម្រេចរឿង នេះ ។ ខ្ញុំក្អួត, ក្អួតរហូតទាល់តែអស់ពីពោះ, ហើយក្លិនថ្នាំសណ្តំនេះធ្វើឱ្យខ្ញុំស្ទើរវិលមុខជាថ្មីម្តងទៀត។
ក៏ប៉ុន្តែមិនជាអ្វីទេពិសពុលទាំងឡាយ ដែលសម្ងំក្នុងក្រពះខ្ញុំដើម្បីផ្សាយអានុភាព, ឥឡូវនេះវាចេញមកក្រៅអស់ទៅហើយ ...

ខ្ញុំកកិលខ្លួនជាថ្មីម្តងទៀតដើម្បីទៅកាន់គ្រែ, បំពង់កខ្ញុំស្ទើរ រហែកដោយ សារការខំប្រឹងខាកនិងប្រឹងក្អួត, មុខរបស់ខ្ញុំទទឹកដោយ សារទឹកដែលខ្ញុំលុបមុខឥត ឈប់ឈរសោះ,អស់ជាច្រើននាទី។ ក៏ ប៉ុន្តែខ្ញុំមានការប្រុងប្រយ័ត្នណាស់ ពុំឱ្យសម្លៀក បំពាក់របស់ខ្ញុំទទឹក បន្តិចឡើយ ។

មិនគ្រាន់តែប៉ុណ្ណោះទេ ។ មុននឹងចេញពីបន្ទប់ទឹកមកខ្ញុំបាន រៀបចំយ៉ាង ស្អាតមិនទុកអ្វីជាស្លាកស្នាមឡើយមុននឹងខ្ញុំវិលមកកាន់ គ្រែនេះវិញ ។ អាឧត្បាត ទាំងនេះអាចនឹងដឹងរឿងនេះនៅពេលដែល វាត្រឡប់មកវិញ ។

ឥឡូវនេះខ្ញុំត្រូវលៃលកយ៉ាងណា ដើម្បីចេញឱ្យផុតពីផ្ទះដ៏ចង្រៃ ឧត្បាតនេះ ។ ហើយដល់ពេលនោះ ខ្ញុំអាចនឹងស្រែកបង្ហូកហៅឱ្យគេជួយខ្ញុំគ្រប់ទិសទីបាន ។ ប៉ុន្តែអនិច្ចា ! ពុំដឹងជាហេតុអ្វីស្រាប់តែខ្ញុំផ្ងាកទៅក្រោយហើយក្បាលខ្ញុំកើយលើខ្នើយ ។ នៅក្នុងអាការៈដ៏ហត់ហេវកម្លាំងនេះ, មនសិការខ្ញុំឆ្លើយដោយស្រួលថា "ខ្ញុំដេក សម្រាកតែ១០នាទីទេ, ខ្ញុំនៅសល់ពេលយ៉ាងតិចណាស់ក៏មួយ ម៉ោងដែរ ។ ពួកឧត្បាតអស់នោះវាថា វានឹងត្រឡប់មកវិញ នៅម៉ោង ១២ កន្លះរំលងអាធ្រាត ។

ខ្ញុំត្រូវតែគេងយកកម្លាំង, ខ្ញុំមិនឱ្យខកខ្លួនក្នុងការដេកនេះឡើយ, ដោយហេតុថាខ្ញុំបានក្អួតចោល អស់នូវថ្នាំសណ្តំនេះហើយ ... "

ទោះបីខ្ញុំជាមនុស្សដែលមានមហិទ្ធិឫទ្ធិខាងផ្លូវចិត្តយ៉ាងដូចម្តេច ក្តី, ក៏ពលំកាយរបស់ខ្ញុំទ្រុឌទ្រោមអស់ហើយ ឯការងងុយក៏លុក ទន្ទ្រានក្នុងពិភពនេត្រារបស់ខ្ញុំ ។ ដោយចលនាដៃដ៏ទន់ល្វតល្វើយ, ខ្ញុំពន្លត់ចង្កៀង ... ពេលវេលាកន្លងទៅយ៉ាងយឺតៗ , ដោយសេចក្តី អាណិតអាសូរ ។ ក៏ប៉ុន្តែមនសិការមិនបានលះបង់ខ្ញុំចោលឡើយ . . .

ស្រាប់តែមួយរំពេចនោះ ខ្ញុំភ្ញាក់ខ្ញាក ហើយខ្ញុំត្រូវចំណាយពេល អស់ច្រើននាទីដើម្បីរំឭកព្រឹត្តិហេតុដែលកន្លងទៅ ។ នៅពេលដែល ខ្ញុំបានវិលត្រឡប់មក ជួបនឹងប្រាកដនិយមវិញ, គឺជាប្រាកដនិយមដ៏គួរឱ្យតក់ស្លុតមួយ, ថាខ្ញុំកំពុងតែស្ថិតនៅក្នុងក្រញាំបិសាច, ខ្ញុំហៀប នឹងស្រែកទៅហើយ, ស្រាប់តែបបូរមាត់ខ្ញុំខ្ទប់សម្លេងនេះមិនឱ្យខ្ទាត ចេញមកក្រៅឡើយ ។ ខ្ញុំបន្ទោសអាត្មាឯងថា "ហេតុអ្វីបានជាខ្ញុំឆ្កួតទៅបណ្តោយអាត្មាឱ្យស្ថិតក្រោមអនុភាពនៃការងងុយដូច្នេះ, ត្រង់ ដែលថាខ្ញុំត្រូវចំណាយពេលវេលានេះ ដើម្បីរិះរកមធ្យោបាយរត់ គេចខ្លួននោះយ៉ាងណាទៅវិញ !"

ប្រហែលជាពួកវាវិលត្រឡប់មកវិញទេដឹង នៅពេលដែលខ្ញុំ កំពុងតែដេកនោះ ? ឱព្រះពុទ្ធជាម្ចាស់អើយ ! ឱព្រះពុទ្ធជាម្ចាស់អើយ ! ឱព្រះពុទ្ធជាម្ចាស់អើយ !

ខ្ញុំផ្ទៀងសោតាស្តាប់, បន្ទាប់មកដោយចលនាដៃដ៏ស្ទាក់ស្ទើរ របស់ខ្ញុំ, ខ្ញុំចុចគន្លឹះចង្កៀងបំភ្លឺវិញ ។ ដោយសេចក្តីរំភើបញាប់ញ័រ ខ្ញុំមើលនាឡិកា ។ ម៉ោង១២និង១៧នាទីទៅហើយ ! គិតទៅខ្ញុំ បានដេកជិត១ម៉ោង, គឺការសំរាកនេះហើយដែលញ៉ាំងឱ្យខ្ញុំមានកម្លាំងឡើងវិញ ។

ខ្ញុំក្រោកឡើងអង្គុយបានដូចបំណង . . . ខ្ញុំដាក់ជើងចុះទៅលើកម្រាលឥដ្ឋ, ខ្ញុំធ្វើបានដូចបំណង ។ ខ្ញុំក្រោកឈរជើងទាំងពីរទ្ររាងកាយរបស់ខ្ញុំរួច ។ ខ្ញុំបោះជំហាន

១ ២ ! ១ ២ ! ជំហានរបស់ខ្ញុំដើរ ទៅមុខបានយ៉ាងស្រួល ។ ខ្ញុំក៏ស្ទុះសំដៅទៅបង្អួច យកដៃញែកវាំងននដែលបាំងពីក្នុង, ដើម្បីចោលនេត្រាមើលទៅខាងក្រៅ ។ អនិច្ចា ! គ្មានបង្អួចឯណាទេ គឺជាជញ្ជាំងស្មោះ, គេបានដាក់តែមឈើ, គឺបាន ដាក់វាំងនន គឺដើម្បីបំភ័ន្តភ្នែកអ្នករងគ្រោះតែប៉ុណ្ណោះ ដូច្នេះទីនេះ គេបានគ្រោងទុកយ៉ាងប៉ិនប្រសប់បំផុត ។ តើនៅទីនេះមានមនុស្ស រងគ្រោះប៉ុន្មាននាក់ហើយ , តើខ្ញុំនៅក្នុងបន្ទប់នេះធ្វើអ្វី ? កុំថា ឡើយតែខ្លាញី, សូម្បីតែកន្លាតជាសត្វដ៏ល្អិតក្នុងគ្រាដែលវាទាល់ច្រក ដូច្នេះវាត្រូវតែមុជរិះរក ត្បុលខាងណេះ ត្បុលខាងណោះ ដើម្បីសង្គ្រោះខ្លួនវាដែរខ្ញុំដើរសំដៅទ្វារហើយ សេចក្តីសង្ឃឹមរបស់ខ្ញុំក៏រស់ រវើកឡើងវិញ ។ កូនសោនៅទីនេះ ។ ឧក្រិដ្ឋជន ឥតបានចាក់សោ ទ្វារនេះឡើយ, ពីព្រោះអ្វី ? គ្មានអ្វីគួរឱ្យសង្ស័យឡើយ ឧក្រិដ្ឋជន ដែលមានការពិសោធន៍ជាច្រើនណាស់មកហើយនោះ សុទ្ធតែយល់ថា អ្នករងគ្រោះពុំអាចភ្ញាក់ពីភាពសណ្តំរបស់ខ្លួនមុនម៉ោង២នេះឡើយ ។ ដោយការពិសោធន៍ជាច្រើនដងមកហើយនោះ , ឧក្រិដ្ឋជនពុំយកចិត្តទុកដាក់ចំពោះទ្វារនិងកូនសោនេះប៉ុន្មានឡើយ ព្រោះថាគេនឹងវិល ត្រឡប់មកវិញមុនពេលអ្នករងគ្រោះដឹងខ្លួន ។ គេធ្លាប់ដឹងនិងធ្លាប់ ឃើញតែដូច្នេះ ...

ក៏ប៉ុន្តែការស្មានរបស់វាខុស ព្រោះខ្ញុំពុំបានបណ្តែតបណ្តោយ អាត្មាខ្ញុំឱ្យលុះនៅក្រោមសេចក្តីតក់ស្លុតរហូតទាល់តែភ្លេចខ្លួនភ្លេច ប្រាណនោះទេ ហើយម្យ៉ាងទៀតកម្ហួតរបស់ខ្ញុំអាចនឹងបន្ថយបន្សាយ អានុភាពនៃថ្នាំសណ្តំនេះ ដែលហេតុបណ្តាលឱ្យខ្ញុំភ្ញាក់មុនពេលឧក្រិដ្ឋជនស្មាន ។

ដោយកម្លាំងដៃរបស់ខ្ញុំ, ខ្ញុំក៏បើកទ្វារនេះបានដោយហាត់គឃូ ។

រាត្រីកាល ខ្មៅងងឹតចាក់ភ្នែកពុំយល់ ពីលើក្បាលជណ្តើនេះធ្វើ ឱ្យខ្ញុំមានសេចក្តីតក់ស្លុតតក្កមា ។ ក៏ប៉ុន្តែសភាពស្ងប់ស្ងាត់បានធ្វើឱ្យខ្ញុំ មានការនឹងនក្នុងចិត្ត ។

ខ្ញុំមានសេចក្តីសង្ឃឹមមួយ, ពីព្រោះថាមាន ឧក្រិដ្ឋជនតែ២ នាក់ប៉ុណ្ណោះនៅក្នុងផ្ទះនេះ, មិនថាអ៊ីចឹង ?

តើកុងតាក់ភ្លើងនៅឯណា, នៅឯណា? ពេលនេះខ្ញុំត្រូវការកុង តាក់ភ្លើងជាចាំបាច់បំផុតដូចដែលរថយន្តត្រូវការចង្កូតឥតចៀសបានឡើយ ។

ខ្ញុំនឹកស្ញើបនៅឯបាតជើងរបស់ខ្ញុំខ្លាំងណាស់ , ពីព្រោះខ្ញុំព្រួយបារម្ភខ្លាច ជើងនេះជាន់ទៅនឹងកន្លែងទទេ ហើយខ្លួនខ្ញុំនឹងធ្លាក់ ទៅក្នុងអន្ទាក់ណាមួយដូចជាអន្លុងដែលមានចម្រឹងដែក, ដូចជា កន្លែងទ្រុងរបស់សត្វចចក ឬគុហាមួយដែលមានលលាដ៏ក្បាលខ្មោច និងឆ្អឹងឆ្អែងរកេតរកូតមីដេរដាស ... អ្នកណាដឹងបាន ? ខ្ញុំស្រមៃសព្វគ្រប់បែបយ៉ាង ដូចដែលខ្ញុំបានអានប្រលោមលោកដ៏គួរឱ្យព្រឺ គប់រោម, ដែលគេនិយាយអំពីវិមានរបស់បិសាច ...

ដៃរាវស្ទាបជញ្ជាំងជានិច្ច ហើយស្រាប់តែប៉ះនឹងរបស់អ្វីមួយដែល ខ្ញុំយល់ថាជាកុងតាក់ភ្លើងខ្ញុំក៏ចុចគន្លឹះវា ។ ពន្លឺបានជះ តាមជណ្តើរដែលមានជញ្ជាំងពីរអមជិតបីដូចជាទ្រុងដូច្នោះ ។ គឺជា ជណ្តើរដ៏ចាស់រិចរិល ...

ពេលវេលាខ្លីណាស់នៅសល់តែជាង ១០នាទីប៉ុណ្ណោះ ខ្ញុំក៏ឈាន ជើងចុះតាមជណ្តើរ ដែលមានកាំទំហំតូចៗ ហើយជួនកាលខ្ញុំលោត ដោយសារកាំជណ្តើរនេះប្រេះពុក ព្រោះស៊ីម៉ងត៍ចាស់យូរឆ្នាំ ។ បន្ទប់ នៅខាងលើដែលខ្ញុំទើបនឹង ចាកចោលមកនេះគឺជាបន្ទប់តែមួយគត់ដែលមានសង្ហារិមភ័ណ្ឌនិងបន្ទប់ទឹក ។

ដូច្នេះវិមាននេះគឺជាវិមាន ដែលឧក្រិដ្ឋជនយកជនរងគ្រោះមកដាក់នៅទីនេះ មុននឹងនាំទៅកាន់ទីដទៃទៀត ... ខ្ញុំចុះជណ្តើរមកដល់ជាន់ខាងក្រោម ជញ្ជាំងហ៊ុំព័ទ្ធជិតទៀត ។ ខ្ញុំពុំទាន់បានចេញផុតអំពីព្រំដែននៃវិមាននេះនៅឡើយ ទេ, ខ្ញុំសង្ឃឹមថាកាលបើខ្ញុំចុះផុតជណ្តើរ, ខ្ញុំនឹងបានឃើញផ្ទៃមេឃ និងដួងតារាទាំងឡាយ ។

ក៏ប៉ុន្តែអនិច្ចា ! សេចក្ដីសង្ឃឹមរបស់ខ្ញុំរលត់រលាយភ្លាម ។ ខ្ញុំគ្មានឃើញផ្ទៃមេឃ ប៉ុនបាតដៃ ឬដួងតារាមួយគ្រាប់ឡើយ, តើខ្ញុំស្រែកឱ្យនរណាស្ដាប់, ឱ្យនរណាឮ, មិនបានន័យថាខ្ញុំ ស្រែកដើម្បីវិមាននេះទេឬ ?

នេត្រារបស់ខ្ញុំក្រឡេកទៅឆ្ងាយក៏ប្រទះឃើញទ្វារដែកមួយដ៏មាំមួន ។ ខ្ញុំស្ទុះទៅ, សេរីភាពខ្ញុំនៅត្រង់ទ្វារនេះ, ជីវិតខ្ញុំនៅត្រង់ទ្វារនេះ បើទ្វារនេះរបើកហើយ ប្រហែលជាសេចក្ដីតក់ស្លុតរបស់ខ្ញុំនឹងរលត់រលាយជាពុំខានឡើយ ...

ប៉ុន្តែអនិច្ចា ! នៅពេលដែលខ្ញុំមកដល់ទ្វារនេះ ទើបខ្ញុំដឹងថា ខ្ញុំធ្លាក់នរកម្ដងទៀតហើយ ។ ទ្វារនេះឥតមានគន្លឹះអ្វីទាំងអស់ ។ ចុះ ហេតុអ្វីក៏វារឹងម៉ឹងម្ល៉េះ ? ក្នុងខណៈនោះ, ខ្ញុំយល់ហើយថាគន្លឹះគេ ដាក់នៅខាងក្រៅឯណោះ គឺថាទ្វារដែលគេធ្វើឡើងតាមរបៀបទ្វារគុក ។ វិមាននេះគេសង់ឡើងសំរាប់តែធ្វើឧក្រិដ្ឋកម្មប៉ុណ្ណោះ , គឺថាគេបានរៀបដើងព្រួលសម្រួលជើងការណ៍យ៉ាងស្រេចបាច់អស់ . . .

ហួសពីខ្លាច, ខ្ញុំលែងខ្លាចព្រោះខ្ញុំយល់ច្បាស់ថា សេចក្ដីសង្ឃឹម របស់ខ្ញុំរលត់រស្មីហើយ ។ ខ្ញុំដើររុកកកាយឱ្យតែឃើញមានច្រក, គឺ ច្រកចេញ ។ ក៏ប៉ុន្តែច្រមុះរបស់ខ្ញុំប៉ះតែនឹងជញ្ជាំងគ្រប់ទិសទី ។

ក្នុងពេលនោះ ខ្ញុំហាក់ដូចជាធុំក្លិនអ្វីដែលហៅថាក្លិនដុះផ្សិត ។ ខ្ញុំក៏ដើរចូលក្នុងបន្ទប់មួយនោះ ។ គឺជាបន្ទប់ផ្ទះបាយ ។ វត្ថុទីមួយ ដែលខ្ញុំបានឃើញគឺបង្អួចនៅឯជញ្ជាំង ។ ខ្ញុំស្ទុះទៅជាថ្មីដោយសង្ឃឹមថា បង្អួចនេះនឹងបែរទិសទៅខាងក្រៅវិមានឬចំហៀងវិមាន ដែលខ្ញុំ យល់ថាពិតជាមានភូមិគ្រឹះរបស់អ្នកដទៃ ស្ថិតនៅទីជិត។ ហើយខ្ញុំ នឹងខំប្រឹងស្រែកឡើងទាញយកសេចក្ដីប្រុងប្រយ័ត្ន និងជំនួយពីពួកនៅជិតនេះ ។ ខ្ញុំនៅសល់៧ ឬ ៨នាទីទៀតដែរ ដើម្បីផ្សងសំណាង ។ អនិច្ចានៅពេលដែលខ្ញុំមកដល់, ពុំមែនជាបង្អួចពិតនោះទេ គឺជាបង្អួច ក្រឡៃដូចនៅក្នុងបន្ទប់ខាង

លើដូច្នោះ ។ តើគេសង់បង្អួចក្រឡៃ នេះធ្វើអ្វី ? អស់សង្ឃឹម ខ្ញុំស្រយុតស្រយង់អស់ដួងព្រលឹង ...

ក៏ប៉ុន្តែខ្ញុំមិនចាញ់ទេ ។ ខ្ញុំលើកដៃតប់ជញ្ជាំងត្រង់បង្អួចនេះ ៣ ៤ ដៃ ដោយសង្ឃឹមថាក្រែងជាទ្វារសម្ងាត់អ្វីអាចចេញទៅបាន ។

ជាការធម្មតាទេ ក្នុងវិមានឧក្រិដ្ឋកម្មមានកន្លែងបិទជិត ក៏មែនពិត ហើយ ប៉ុន្តែត្រូវតែមានច្រកសម្ងាត់សំរាប់ចេញទៅដែរ ក្នុងពេល ឧក្រិដ្ឋជននោះត្រូវប៉ូលិសរកមុខឃើញ, ហើយដែលជាពន្លឹចុងក្រោយ បំផុតសំរាប់ឧក្រិដ្ឋជនក្នុងការភៀសខ្លួនចេញ អនិច្ចា, ជញ្ជាំងគឺ ជញ្ជាំងដដែល, ខ្ញុំបែរក្បាលផាំងរេមើលក្នុងបន្ទប់ ។ ក្បាលម៉ាស៊ីនទឹកមួយក្រខ្វក់ ហើយទឹកនៅស្រក់តក់ៗ នៅឡើយ ។ គ្រប់ទីកន្លែង មានភាពក្រខ្វក់និងក្លិនដុះផ្សិតដែលជាសញ្ញាឱ្យយល់ថា ផ្ទះបាយនេះ គេឥតប្រើប្រាស់ឡើយ ។ នៅឯជ្រុងម្ខាងតុកំបាក់ជើងមួយនៅទីនោះ ហើយនៅពីលើ ខ្ញុំឃើញនំប៉័ងប្រវែងមួយចំអាមនិងត្រីខកំប៉ុង ដែលបើកហើយស្រេចនៅសល់ជាងពាក់កណ្តាល ។ ដូច្នេះឧក្រិដ្ឋជនម្នាក់ឬពីរ នាក់នេះ ពិតជាបានចូលមកក្នុងបន្ទប់នេះ ក្រោយពីបានគ្រាហ៍ខ្ញុំយក ទៅចោលនៅឯក្នុងបន្ទប់ខាងលើឯណោះ ។ ហើយដោយឃ្លានពេក គេក៏ប្រញាប់ប្រញាល់បរិភោគដើម្បីចេញទៅខាងក្រៅ ... ដូច្នេះខ្ញុំ មិនត្រូវទុកដានឬស្លាកស្នាមអ្វីក្នុងទីនោះឡើយ ។ ក៏ប៉ុន្តែមុននឹងខ្ញុំ ចេញ ភ្នែករបស់ខ្ញុំខំរេរកគ្រប់កន្លែងក្រែងឃើញមានកាំបិត ឬអាវុធ អ្វីមួយសំរាប់ជាមធ្យោបាយជួយដោះគ្រោះរបស់ខ្ញុំ ។

គ្មានអ្វីសោះ, គ្មានអ្វីទាល់តែសោះ ។ ព្រោះវិមាននេះ វិមានដ៏ចាស់នេះ វិមានបិសាចនេះ ពុំមែនសម្រាប់អាស្រ័យនៅទេគឺសំរាប់ ធ្វើជាមន្ទីរឃុំឃាំងអ្នករងគ្រោះ ...

ខ្ញុំបើកថតតុ ខ្ញុំរើកកាយកន្លែងខ្លះៗ ដោយប្រុងប្រយ័ត្ន ប៉ុន្តែ ខ្ញុំគ្មានប្រទះនឹងអ្វីសោះ ។ ស្រាប់តែមួយរំពេចនោះនៅលើតុមានវត្ថុ មួយដែលបានទាញសេចក្ដីប្រុងប្រយ័ត្នរបស់ខ្ញុំ គឺជាសេចក្ដីសង្ឃឹម ដ៏តូចមួយ ។ តើវត្ថុនោះពុំមែនជាអាវុធទេឬ ? គឺជាអាវុធទន់ ខ្សោយពិបាកប្រើប្រាស់ ក៏ប៉ុន្តែវាជាអាវុធមួយដែរ ... ក្នុងគ្រា ខ្យល់ព្យុះខ្លាំង, ម្ចាស់សំពៅមិនចាំបាច់រើសកំពង់ផែទេ ... ផែណាក៏ដោយឱ្យតែផែ គេត្រូវតែចូលចតសិន ! ក្នុងពេលតណ្ហាកម្រើកខ្លាំង, បុរសស្ត្រីមិនចាំបាច់រើសគូប្រយុទ្ធស្អាតល្អនោះទេ, ល្មមៗ ក៏បានដែរ ឱ្យតែគូប្រយុទ្ធមានប្រដាប់សំរាប់ប្រើប្រាស់ បំរើកាមកិលេសរបស់ខ្ញុំ, មិនថាអ៊ីចឹង ?

ខ្ញុំក៏ចាប់អាវុធនេះក្ដាប់ក្នុងដៃ ។ រួចខ្ញុំថយក្រោយហើយខ្ញុំដើរ យ៉ាងប្រុងប្រយ័ត្ន ដោយពន្លត់ចង្កៀងនៅពេលដែលខ្ញុំឡើងផុតជណ្ដើរ ។ ខ្ញុំឡើងជណ្ដើរដើម្បីវិលមកក្នុងបន្ទប់របស់ខ្ញុំវិញ , ក្រោយពីការដើរអស់រយៈកាលជាង១០នាទី ទាំងឥតប្រយោជន៍ ។ មែន កាលដំបូងខ្ញុំចុះទៅខាងក្រោម ជាសេចក្ដីប្រាថ្នារបស់ខ្ញុំតែមួយដើម្បីរត់ភៀសខ្លួន ព្រោះតែហេតុនេះហើយបានជាខ្ញុំភ្លេចមើលអ្វីៗទាំង អស់នៅឯជាន់ខាងលើជិតបន្ទប់របស់ខ្ញុំ ។ នៅក្បែរបន្ទប់ខ្ញុំ, ខ្ញុំឃើញ បន្ទប់តូចមួយទៀត ... បន្ទប់ស្អី ? ខ្ញុំនឹកព្រឺខ្លួន, ក្រែងជាបន្ទប់ ដែលគេដាក់ខ្មោចទេដឹង ? គឺជាបន្ទប់បិសាចឬបន្ទប់ធ្វើឃាដមនុស្ស ទេដឹង ?

មិនជាការចម្លែកទេ ក្នុងវិមានមួយដែលឧក្រិដ្ឋជនសាងសំរាប់ ប្រព្រឹត្តឧក្រិដ្ឋកម្មនេះរបស់ខ្លួននោះ គេតែងតែសាងកន្លែងមួយសំរាប់ លាងឧក្រិដ្ឋកម្មនេះដែរ ។ ឧបមាថាបើឧក្រិដ្ឋជននេះភ្លាត់ស្នៀត ឧបមាថា បើអ្នករងគ្រោះនេះមានសំណាងដោយប្រការណាមួយក្នុង ការស្គាល់មុខឧក្រិដ្ឋជននេះ ការតែម្យ៉ាងដែលគេធ្វើចំពោះអ្នករងគ្រោះគឺសេចក្ដីស្លាប់ ...

ខ្ញុំយកដៃច្រានទ្វារបន្ទប់នេះសាកមើល ។ ទ្វារក៏របើកថ្នមៗ ដោយបញ្ចេញសូរស័ព្ទលាន់ទ្រហឹង ដែលបណ្ដាលឱ្យខ្ញុំព្រឺខ្នាកៗ ក្នុង ខ្លួន, ក្រែងភ្នែករបស់ខ្ញុំប៉ះលើទស្សនីយភាពដ៏ឃោរឃៅណាមួយ ។ បន្ទប់ងងឹតឈឹង ។ កែវភ្នែករបស់ខ្ញុំដែលមានទម្លាប់ក្នុងអន្ធការទៅហើយនោះ, ខ្ញុំប្រទះឃើញកុងតាក់ភ្លើងមួយ ។ ខ្ញុំក៏ចុចគន្លឹះនេះភ្លាម, រស្មីអគ្គិសនីក្រហមប្រេញជះពេញក្នុងបន្ទប់ ដែលគ្មានភាពស្អាតស្អំបន្តិចសោះ ។ ក្នុងមួយខណៈនោះឯងនេត្រាខ្ញុំស្រវាំង ហើយបេះដូងខ្ញុំគាំងអស់ ។ តើខ្ញុំឃើញអ្វី ? តើខ្ញុំឃើញអ្វី ?

ឱព្រះអើយ ! ឱព្រះអើយ ! ទូរស័ព្ទមួយនៅទីនេះគឺទូរស័ព្ទមួយ ! សេចក្ដីសង្ឃឹមមួយ ! គឺជីវិតថ្មី !

ខ្ញុំហាក់សំដៅទូរស័ព្ទនេះដូចជាសិង្ហលោតសំដៅឈ្លូស ដែលជា ភក្សាហាររបស់ខ្ញុំដូច្នោះ ។ ខ្ញុំលើកដៃទូរស័ព្ទ ... ហើយក៏រវៃលេខ ផ្ទះរបស់ខ្ញុំ ។ សូររោទិ៍ទូរស័ព្ទនៅឆ្ងាយឯណោះ បន្លឺឡើងយ៉ាងវែង យ៉ាងយូរ, មួយនាទីសំរាប់ខ្ញុំ ហាក់បីដូចជាមួយម៉ោង, យូរអ្វីម្ល៉េះ ? គ្មាននរណាឆ្លើយតបសោះ ។ ខ្ញុំយកដៃសង្កត់គន្លឹះទូរស័ព្ទដើម្បីផ្ដាច់ ការទាក់ទងលើកទី១ ហើយខ្ញុំក៏រវៃលេខថ្មីដើម្បីហៅបងវិចិត្រ ។ សូររោទិ៍ឯឆ្ងាយឯណោះក៏បន្លឺជាថ្មីទៀត ។ រោទិ៍យូរ អើយសែនយូរ, ក៏ប៉ុន្តែគ្មាននរណាឆ្លើយសោះ ។ តើបងវិចិត្រកំពុងតែតាមរកខ្ញុំទេដឹង ?

ខ្ញុំនឹកឃើញប៉ូលិស ។ តើទូរស័ព្ទរបស់ប៉ូលីសលេខប៉ុន្មានទៅ ? មិនដឹងទាល់តែសោះ ។

ស្រាប់តែមួយរំពេចនោះ ខ្ញុំគាំងខ្លួនបីដូចជាចរន្តឈាមលែងរត់ ដូច្នោះ ។ ស្នូររថយន្តមួយបន្លឺនៅឯផ្លូវខាងមុខឯណោះ ។

យឺតណាស់ហើយសំរាប់ខ្ញុំ ! ខ្ញុំគ្មានពេលដើម្បីរំដោះខ្លួនខ្ញុំទៀត ទេ ! ពួកឧត្បាតនឹងមកដល់ហើយ កាលបើវាដឹងថាខ្ញុំនៅទីនេះ , វានឹងសម្លាប់ខ្ញុំ ព្រោះវាមានកាំភ្លើងមួយ, នេះជាការឥតសង្ស័យឡើយ ... ខ្ញុំលូកដៃចុចពន្លត់ចង្កៀងក្រោយពីដាក់ដៃទូរស័ព្ទគងត្រឹមត្រូវហើយ ។

ខ្ញុំបិទទ្វាររួចក៏ចូលក្នុងបន្ទប់របស់ខ្ញុំវិញ, ក្នុងពេលនោះ ខ្ញុំឮសូរទ្វារដែកឯក្រៅបើកគ្រាំង១ ឡើង ។ ឡានដែលចូលមកម្តងនេះ, តាមសំដីដែលឧក្រិដ្ឋជននិយាយថា ជាឡានពេទ្យដែល កំពុងតែចូលចតនៅឯទីធ្លា ។ ខ្ញុំច្រានទ្វារបន្ទប់របស់ខ្ញុំបិទមកវិញ ដូចគ្រាដើមដូច្នោះ ។

ខ្ញុំចិញ្ចឹមសេចក្តីសង្ឃឹមថ្មីមួយទៀត ពីព្រោះឧក្រិដ្ឋជននឹងជឿថា ខ្ញុំនៅតែពុលថ្នាំនៅឡើយ ។ បើទេវតាប្រោសប្រណីឱ្យខ្ញុំនៅបន្ទប់នេះ ៤-៥ នាទីជាមួយនឹង "អាប្រុស" នោះប្រហែលជាខ្ញុំមាន ភ័ព្វសំណាង ។ គឺថាក្រោយពី "អាប្រុស" នេះរងគ្រោះដោយសារ អាវុធរបស់ខ្ញុំហើយ "មីស្រីប្រហែលជាគ្មានលទ្ធភាពនឹងចាប់គ្រញិចខ្ញុំដោយដៃទទេ ទេដឹង ។

ខ្ញុំឡើងលើគ្រែ ហើយគេងសណ្តូកកាយធម្មតា ខំទប់អារម្មណ៍ និងជីពចររបស់ខ្ញុំកុំឱ្យលោតខ្លាំងពេក ។ នៅឯខាងក្រោមខ្ញុំឮសូរទ្វាររណ្តំគ្នា ហើយរបើកឡើងបន្ត១ គ្នា រួចបន្ទាប់មកស្នូរឡើងជណ្តើរមួយ១ ...

តាមខ្ញុំយល់ការចេញដំណើរតាមឡានពេទ្យ ពុំមែនធ្វើឡើងភ្លាមនោះទេ តើពួកឧក្រិដ្ឋជននេះត្រូវការអ្វីទៀត ។

ខ្ញុំនឹកឃើញរឿងមួយនោះ ខ្ញុំតក់ស្លុតឡើងព្រឺខ្លួន ។ "អាប្រុស" នោះពុំមែនជាតាចាស់នោះឡើយ ។ សំដីរបស់វា ដៃរបស់វាដែល កាន់ចង្កូតរថយន្តបញ្ជាក់ឱ្យដឹងជាភ័ស្តុតាងស្រាប់ ។ ដូច្នេះខ្ញុំត្រូវធ្វើការប្រយុទ្ធ ជាមួយនឹងបុរសមួយរូបដែលកំពុង

ពេញកម្លាំង ។ ក្នុងពេលជាមួយគ្នា ខ្ញុំរលឹកឃើញរឿងព្រេងនិទានដែលគេតែងនិយាយអំពីសត្វក្ដាន់ធ្វើពុតជាស្លាប់ ដើម្បីឆ្លៀតឱកាសរំដោះខ្លួនបានក្នុងពេល ដែលអ្នកស្រែម្ចាស់អន្ទាក់ពុំបានចាប់ភ្លឹក ។ ខ្ញុំក្ដាប់អាវុធ ដ៏តូចនេះ ជាប់ ហើយខ្ញុំបន្លំដាក់ដៃក្រោមកម្រាលពូកដែលឧក្រិដ្ឋជនបានដណ្ដប់ឱ្យខ្ញុំ ។

ខ្ញុំឮសូរក្បាលត្រមោងទ្វារកម្រើកក្រិចក្រុកៗ រួចទ្វារក៏របើកឡើង ...

ខ្ញុំខំទប់ចេតនារម្មណ៍និងបសាទរបស់ខ្ញុំទាំងមួយពាន់ ដើម្បីកុំ ឱ្យខ្ញុំធ្វើចលនាអ្វីដែលបណ្ដាលឱ្យឧក្រិដ្ឋជនដឹងនិងទាយថា ខ្ញុំនេះពុំ មែនសន្លប់ដូចដែលវាស្មាននោះទេ ។ ឱះ ឱ វានឹងបើកភ្លើងឥឡូវ ហើយ ! ហើយកាលបើភ្លើង អគ្គិសនីបំភ្លឺមក តើត្របកភ្នែករបស់ ខ្ញុំកម្រើកទេ ? អុយ ! ខ្ញុំខំទប់រកអ្វីប្រៀបផ្ទឹមពុំបាន . . .

ខ្ញុំឮសូរក្រឹក, គឺជាគន្លឹះអគ្គិសនីដែលវាទើបតែនឹងចុច . . .

៩

## អាវុធដ៏សក្តិសិទ្ធ

នៅពេលដែលភ្លើងអគ្គីសនីភ្លឺឡើង, ខ្ញុំស្រែកអំពាវនាវក្នុងចិត្តខ្ញុំ ហៅគ្រប់វត្ថុស័ក្តិសិទ្ធិទាំងឡាយ ដើម្បីមកជួយទប់កាយវិការត្របក ភ្នែកនិងលក្ខណៈនៃមុខរបស់ខ្ញុំកុំឱ្យញោច ឬកុំឱ្យមានចលនាអ្វីខុស អំពីធម្មជាតិរបស់មនុស្សសន្លប់នោះឱ្យសោះ ។ ខ្ញុំប្រហែលជាបាន សម្រេចហើយបានជាខ្ញុំឮសម្លេងរបស់ឧក្រិដ្ឋជន "អាប្រុស" និយាយថា : នាងដេកយ៉ាងឆ្ងាញ់ដដែល !

ឧក្រិដ្ឋជន "មីស្រី" ក៏សួរថា :

តើខ្ញុំត្រូវចាក់ថ្នាំឱ្យវាភ្លាមឬ ?

ឮពាក្យថាចាក់ថ្នាំ, ឈាមខ្ញុំកញ្ជ្រោលពុះផុសឡើងបីដូចជាទឹក ដែលធ្លាក់មកពីលើកំពូលភ្នំច្របល់បែកខ្ចូរខ្ចាយនៅក្នុងជ្រោះដូច្នោះ ។

- កុំទាន់អី, "អាប្រុស" និយាយ ។ គួរទៃទុកឱ្យមីចាបញីនេះ ភ្ញាក់ឡើងវិញសិន ។ មិនយូរទេ, អានុភាពនៃថ្នាំសណ្តំជិតអស់ហើយ "អាស្រី" ឯងទៅរៀបចំថ្នាំដើម្បីនឹងចាក់ឱ្យវាចុះ ហើយកុំភ្លេចភ័ស្តុភា ដែលយើងត្រូវបរិភោគតាមផ្លូវណា៎ !

- ទុកចិត្តលើខ្ញុំចុះ, "មីស្រី" ឆ្លើយតប ។

- បើអីចឹង "អាស្រី" ឯងចុះទៅឯក្រោមរៀបចំកិច្ចចាំបាច់ចុះ ។ រួចទុកខ្ញុំឱ្យនៅតែពីរនាក់មីចាបញីនេះសិន, ដូចដែលខ្ញុំធ្លាប់ធ្វើពីដើមរៀងមក, មិនថាអ៊ីចឹង ?

ទឹកមុខ "មីស្រី" បាក់ជាសម្តែងការមិនពេញចិត្ត ។

- បងផ្លេកឯងគួរឈប់ប្រព្រឹត្តដូច្នេះទៅ ! ព្រោះស្រីនេះស្អាត ល្អជាទីបំផុតហើយតាមមើលប្រហែលជាក្រពុំព្រហ្មចារីទៀតផងបងផ្លេកឯងប្រយ័ត្នខ្លួន ។

ពីដើមខ្ញុំមិនថាទេ ពីព្រោះពីដើមយើងចាប់បានតែស្រីពេស្យា ឬស្រីដែលខូចខ្លួនប្រាណទៅហើយដើម្បីយកទៅឱ្យ "ចៅហ្វាយ" យើងធ្វើការរកស៊ីលក់ដូរតទៅទៀត ។ ក្នុងករណីនោះបងឯងអាចធ្វើអ្វីក៏បានដែរ ពីព្រោះផ្លូវនោះមានគេដើរស្រាប់, គេដើរបន្តពីក្រោយមួយពាន់ដង ក៏គ្មានអ្វីចាប់ភ្លឹកដែរ ... ក៏ប៉ុន្តែមីចាបញីនេះវាជារឿងមិនដូចពួកចាបញីពីមុនៗនោះទេ។

គេជាចាបញីក្រពុំបរិសុទ្ធហើយការដែលដឹងថាក្រពុំបរិសុទ្ធមែន នោះ, "ចៅហ្វាយ" ប្រុសយើងដែលនៅឯដែននាយឯណោះ នឹងឱ្យ រង្វាន់យ៉ាងច្រើនម៉េចបងផ្លេកមិនគិតអំពីរឿងនេះផង ?

បុរសឈ្មោះផ្លេក ក៏បែរមកសម្លឹងមុខសហការិនីរបស់ខ្លួនស្ទើរ ហុតឈាមស៊ីសាច់, ហើយកំហែងថា :

- កាលពីដើមខ្ញុំធ្វើយ៉ាងឥឡូវខ្ញុំត្រូវតែធ្វើយ៉ាងនោះ តើ សមត្ថភាពប្រហែលខ្ញុំ ថ្ងៃណា, ខែណា, ឆ្នាំណា, សតវត្សណា, ខ្ញុំនឹងបាន ពើបប្រទះនូវនារីព្រហ្មចារិនីមានវណ្ណៈនឹងពូជត្រកូលល្អយ៉ាងដូច្នេះបាន ? ឱកាសហុចឱ្យហើយខ្ញុំត្រូវតែ ... មិនថាអ៊ីចឹង ? ហើយ ទោះបីយ៉ាងណាក្តី "អាស្រី" ឯងកុំព្រួយចិត្តថាបងលះបង់ "អាស្រី" ឯងចោល, គឺគ្មានទាល់តែសោះ ។ នេះគឺជាការសប្បាយ នេះគឺជាការជិះក្របីចម្លងភក់, គឺជាក្របីមាស, ក្របីទិព្វក្របីសួគ៌ា ...

បុរសឈ្មោះផ្លេក ច្រានស្ត្រីគូសន្ទនានេះចេញទៅក្រៅ ហើយបិទទ្វារគ្រឹប ! ក្រោយពីកំហែង "មីស្រី" នេះថា :

- កាលណាខ្ញុំធ្វើការមិនទាន់ហើយ ឬខ្ញុំមិនបើកទ្វារឱ្យចូលទេ "អាស្រី" ឯងគ្មានសិទ្ធិអ្វីចូលក្នុងបន្ទប់ខ្ញុំជាដាច់ខាត ។ អើ ! អា ស្រីឯងក៏ដឹងដែរ ថាទ្វារនេះគ្មានសោទេ ព្រោះវាចាស់ហើយនឹងខូចអស់ទៅហើយ ហើយយើងយល់ថាវាគ្មានការ

អ្វីចាំបាច់នឹងធ្វើសោថ្វីសោះ ព្រោះមនុស្សដែលសន្លប់ដោយសារថ្នាំ មានកម្លាំងអ្វីនឹងរត់ទៅ ទីណាកើត ?

សេចក្ដីភ័យតក់ស្លុតរបស់ខ្ញុំដូចដែលខ្ញុំបានគិតទុកនោះ បានមកដល់មែន ។ ថ្វីត្បិតតែខ្ញុំឥតបើកនេត្រាក៏ដោយ, ខ្ញុំក៏អាចយល់បានថា "អាប្រុស" នេះនៅ ក្នុងបន្ទប់ កំពុងសម្លឹងរាងកាយខ្ញុំឥតដាក់ភ្នែកឡើយ ។ ខ្ញុំទាយបានថាវាមើលខ្ញុំ ពីលើចុះទៅក្រោមពីក្រោមឡើងទៅលើ, ជាច្រើនត្រឡប់ជាច្រើនសា ... វាដើរមកក្បែរខ្ញុំ ហើយវាពោលតិចៗ ថា :

- ឱ នារីអីក៏ស្អាតម្ល៉េះ ? ស្អាតម្ល៉េះ ? ខ្ញុំមិនដែលឃើញសោះ ក្នុងលោកនេះ, រង្វង់ភក្ត្រល្អដូចកិន្នរ, កល្អបីដូចហង្សាសុដនដូចជ្រលងសេកមាស, ចង្កេះល្អបីដូចទេពធីតា, ត្រគាកដូចក្អម, កំភួនជើងល្អបីដូចជាសសរថ្លើមថ្ម ...

ខ្ញុំឮសូរដង្ហើមរបស់វាដក មកប៉ះនឹងមុខខ្ញុំ, វាកំពុងតែឈ្ងោកមើលមុខខ្ញុំ ។ រួចវាថើប ហើយវាយកដៃទាំងពីររបស់វាមកច្របាច់សុដនរបស់ខ្ញុំ ។ ឱកាសមកដល់ហើយឬ ? តើខ្ញុំត្រូវប្រើអាវុធដែល នៅនឹងដៃខ្ញុំឬ ? ...

ទេ ! មិនទាន់បានទេ ! ពីព្រោះឧក្រិដ្ឋជនពុំទាន់ស្ថិតនៅក្នុងជំហរមួយដែលខ្ញុំអាចប្រើអាវុធនេះបានសោះ ។ វាបន្តការបបោស អង្អែលតទៅទៀត ហើយដៃរបស់វាលូកដល់ប៊ូតុងសំខាន់របស់ខ្ញុំដែលស្ថិតនៅចន្លោះភ្លៅ ។ ខ្ញុំស្ទើរតែស្រែក ប៉ុន្តែខ្ញុំទប់អារម្មណ៍របស់ខ្ញុំ កុំឱ្យកម្រើរំជើបរំជួល ហើយខ្ញុំជឿជាក់ថា ក្នុងចលនាដែលវានឹងធ្វើក្រោយៗ នេះអាចនឹងហុចស្ថានភាពល្អដល់ខ្ញុំ ដើម្បីប្រើអាវុធរបស់ខ្ញុំ ។ ខ្ញុំធ្វើឬកជាប្រែខ្លួនទៅម្ខាង ហើយខ្ញុំដកដង្ហើមធំ ហាក់បីដូចជា ទើបនឹងស្វាងពីថ្នាំសណ្ដំដែលវាដាក់ឱ្យខ្ញុំដូច្នោះ ។ ខ្ញុំធ្វើជាបើកភ្នែក លឹងឡង់រួចខ្ញុំសួរថា :

- យី ! ចុះកន្លែងនេះជាកន្លែងណា ?

ស្មើនឹងសំណួរ ខ្ញុំក៏ក្រោកអង្គុយ ហើយក្នុងស្ថានភាពរបស់ខ្ញុំដូច្នេះ "អាប្រុស" នោះក៏ថយក្រោយពីរជំហានដើម្បីទុកឱ្យការភ័ន្តភាំងរបស់ខ្ញុំនេះ កន្លងហួសទៅសិន ទើបវាបន្តឧក្រិដ្ឋកម្មក្នុងវិស័យស្នេហារបស់វាទៀត ។ គឺក្នុងស្ថានភាពនេះហើយ ដែលខ្ញុំអាចប្រើអាវុធរបស់ខ្ញុំបាន ។

ឈរឆ្ងាយពីខ្ញុំប្រហែលជាមួយម៉ែត្រកន្លះខ្ញុំក៏រលាស់ដៃស្ដាំយ៉ាងខ្លាំង ហើយ កាលបើចលនានេះកន្លងទៅ, សម្រែកមួយយ៉ាងខ្លាំងក៏បន្លឺឡើងស្ទើរបែកបន្ទប់ អូយ !

. . .

-ម្រេច ! ម្រេច ! ម្រេចចូលភ្នែកអញ ! អៃយ៉ូយ ! អៃយ៉ូយ ! "មីស្រី" ជួយអញផង, ម្រេចចូលភ្នែកអញហើយ ! ម្រេចចូលភ្នែក អញហើយ !

ស្ទុះមករកខ្ញុំ ដែលតាមពិតខ្ញុំលោតចុះពីលើគ្រែរួចហើយនោះ "អាប្រុស" ក៏យកដៃម្ខាងដែលនៅសល់ រាវលើពូកដោយបើកម្រាមឡើង ប្រាថ្នាច្របាច់ កខ្ញុំដោយ កំហឹង ប៉ុន្តែលុះពុំឃើញ, កំហឹងរបស់វាក៏ផ្ទុះបីដូចភ្នំភ្លើង :

- មីចាបញី ! អញ ! អញសុភាពណាស់ បើសិនណាមីចាបញី ឯងយល់រឿង ហើយសុខចិត្តធ្វើតាមបំណងរបស់អញ ...

- អាតិរិច្ឆាន ! អាតិរិច្ឆាន ! ខ្ញុំស្រែកដេរ ។

- ហងរត់មិនរួចពីដៃអញទេ ! ទីនេះនៅឆ្ងាយដាច់ស្រយាល គ្មាននរណាឮឡើយ ! (ឧក្រិដ្ឋជនកុហក់ខ្ញុំ)

ក្នុងកាលៈទេសៈតែមួយនេះខ្ញុំរត់សំដៅមាត់ទ្វារ, ក៏ប៉ុន្តែឧក្រិដ្ឋ ជនវិជ្ជាជីវៈ ដែលមានការពិសោធន៍ច្បាស់លាស់ ក៏ថយខ្លួនទៅឯមាត់ទ្វារនេះមុន ដើម្បីបង្ខាំងកុំឱ្យ "ចាបញីរបស់ខ្លួនរត់រួច" ។ ដៃ ម្ខាងខ្ទប់ភ្នែកទាំងពីរ ដៃម្ខាងដែលនៅសល់ "អាប្រុស" នៅឈរ បង់ជំទែងនៅកន្លែងទ្វារចេញ :

- ឥតប្រយោជន៍ទេ មីចាបញី ! កុំចង់លេងបួនសន្លឹកជាមួយអញ ! អញដើរច្រើននរគហើយហង ... បន្តិទៀតកាលណាភ្នែក របស់អញបានស្រួល លែងឈឺផ្សារអញនឹងឱ្យហងស្គាល់នូវសេចក្ដីទុក្ខមួយ ! អញឱ្យហងសប្បាយជាមួយអញ ២០ ដង ហើយចាំមើល ស្អែកព្រឹកតើហងដើររួចទេ ? ហងនឹងបាក់លោងដូចដង្កូវពុំខាន ! ហងនឹងស្រែកថ្ងូរ, ស្រែករកព្រះកាមទេពឱ្យជួយហង រហូតដល់សន្លប់ ...

- អាតិរិច្ឆាន ! អាតិរិច្ឆាន ! ប៉ូលិសនឹងនាំពួកឯងទៅ ហើយអាឯងនឹងស្គាល់បាតគុកអស់មួយជីវិត ! ខ្ញុំស្រែកដោយកំហឹង ។

- ប៉ូលិស ! ប៉ូលិសឯណាមកដល់ទីនេះ ! ប៉ូលិសពុំមែនមាន ភ្នែកទិព្វត្រចៀកទិព្វនោះទេ ! ហើយប្រសិនបើប៉ូលិសចូលមកដល់ទីនេះមែន, មីចាបញី ! កុំនឹកស្មានថាអញអាផ្លេក ជើងឆ្លងកាត់ពីដែនមកនាយមក មិនមែនឱ្យប៉ូលិសចាប់អញច្រកធុងងាយៗ នោះទេ, អញមានកាំភ្លើងការពារខ្លួនអញដែរ, មិនថាអ៊ីចឹង មីចាបញី ? ហើយ មុននឹងចូលមកដល់ទីនេះ, មីចាបញីឯងក៏ដឹងដែរថា មានឧបសគ្គប៉ុន្មានកន្លែង ?

ស្របពេលជាមួយគ្នានោះ, ទ្វារបន្ទប់នេះក៏របើកយ៉ាំងឡើង ហើយលេចធ្លោរនូវ "មីស្រី" ចូលមក ។

- ស្អី ! កើតមានរឿងស្អី ? ហ៊ា, ម៉េចអ៊ីចឹង ? មីចាបញីនេះ មានកម្លាំងហើយ ?

- កុំទៅរវល់នឹងវាអី ! ជួយមើលភ្នែកអញផង, អញឈឺ ណាស់, ហ៊ . . . រហ័សឡើងមើលភ្នែកអញផង !

- មិនបានទេបងផ្លេក ខ្ញុំឈរចាំត្រង់មាត់ទ្វារនេះ (នាង និយាយផងបិទទ្វារវិញផង) បងផ្លេកឯងកើតអីភ្នែកហ្នឹង ?

- ម្រេច ! ម្រេច, ម្រេច ! កុំសួរហេតុផលច្រើន !

មិនបានទេបងផ្លេក, បងឯងដើរទៅបន្ទប់ទឹកខ្លួនឯងចុះ ខ្ញុំនៅឈរចាំទីនេះ, បើមិនដូច្នោះទេ មីចាបញីនឹងរត់ចេញពីវិមានរបស់យើងបានហើយ រឿងរ៉ាវដែលនឹងកើតឡើងនោះពុំមែនជាល្អសំរាប់យើងទាំងពីរនាក់ឡើយ, មិនថាអ៊ីចឹង ? លាងមុខឱ្យរហ័សទៅខ្ញុំមានសារ៉ាំងនឹងថ្នាំចាំចាត់ការស្រេចហើយ ។

ឮពាក្យសារ៉ាំងហើយនឹងថ្នាំ ខ្ញុំតក់ស្លុតភ្លាម ។ ថ្នាំនេះពុំមែនជា ថ្នាំលើកកម្លាំងឡើយ ខ្ញុំជឿជាក់ថាជាថ្នាំម្ជុលទី២ ដែលមានមហិទ្ធិ ឫទ្ធិជាងថ្នាំសណ្តំ ដែលដាក់លាយក្នុងគ្រាប់ស្ករពីលើកមុន២០ដង ។ គឺជាការពិតណាស់ថា ចាក់ថ្នាំសណ្តំលើកទីពីរនេះ ដើម្បីឱ្យខ្ញុំគេង សន្ទឹងសន្ទៃនៅក្នុងឡានពេទ្យ រួចវានឹងដឹកខ្ញុំទៅកាន់គោលដៅឆ្ងាយ ...តើទៅដល់ទីណាទៅ ?

ខ្ញុំត្រូវតែខំរកវិធីដោះស្រាយឱ្យបានឆាប់រហ័សបំផុត បើមិនដូច្នោះទេ ជីវិតដ៏ឆ្លាតដូចខ្សែអម្បោះរបស់ខ្ញុំនឹងដាក់ហើយ ... សំដី របស់ឧក្រិដ្ឋជនខ្ញុំឮជាក់ច្បាស់ណាស់ថា ការចាប់រូបខ្ញុំមកនេះពុំមែន មានគោលបំណងអ្វីក្រៅពីយកខ្ញុំទៅលក់ឱ្យ "ចៅហ្វាយ" ដើម្បីធ្វើ ជានារីពេស្យានៅឯ ... ឯណាទៅ ? ពុំមែននៅក្នុងប្រទេសកម្ពុជា នេះទេ ដែលជាប្រទេសកំណើតរបស់ខ្ញុំ គឺនៅឯខាងដែននាយឯ ណោះ ...

"មីស្រី" ស្រែកប្រាប់អាប្រុស, ភ្លាមដែលវាកំពុងតែលុបមុខ :

- រហ័សឡើង ! រហ័សឡើងបងផ្លេក ! ខ្ញុំមើលមីចាបញីនេះ កំពុងសម្តែងឫទ្ធិសម្បើមហើយវាប្រុងនឹងរត់ចេញ ។

ផ្លេកហក់ចេញពីបន្ទប់ទឹកមកវិញ ក៏ប៉ុន្តែដៃនៅតែក្តោបភ្នែក ដដែល :

- អៃយូយ ! ភ្នែកអញមើលអ្វីពុំឃើញទេ ! លុមមុខហើយ ក៏ឥតប្រយោជន៍ទៀត ! តើឱ្យអញធ្វើយ៉ាងម៉េច ?

- បងផ្លេកឯងបែរមកខាងកើត ហើយដើរទៅមុខមីចាបញីវា នៅត្រង់នោះឯង ។

ផ្លេកគោរពតាម ដៃម្ខាងខ្ទប់ភ្នែក ដៃម្ខាងរាវស្រវាចាប់ "ចាប ញី" របស់ខ្លួន ។ ខ្ញុំគេចទៅម្ខាង ។ ការគេចការដេញតាម បញ្ជារបស់ "មីស្រី" ឧក្រិដ្ឋនេះឱ្យមនុស្សខ្វាក់តាមក្របួចខ្ញុំ មានភាពល្អមើលណាស់ ប្រសិនបើគេយកទៅបញ្ចាំងជាភាពយន្ត ។

ឧក្រិដ្ឋជនហក់ចូលមកខ្ញុំគេចចេញ ។ ខ្ញុំគេចចេញវាហក់ចូល ។ ចលនាដេញគ្នាបីដូចរស្មីអគ្គិសនីដែលច្របូកច្របល់ដូច្នោះ ។ ខ្ញុំគេច រកព្រះអាយុវាហក់ចូលប្រាថ្នាចាប់ខ្ញុំ ។ ឧក្រិដ្ឋជនដែលខ្វាក់ភ្នែកទាំង ពីរទៅហើយនោះព្រោះវាមើលពុំឃើញ, វាបានដឹងវត្តមានរបស់ខ្ញុំ នៅត្រង់ជ្រុងនេះឬត្រង់ជ្រុងនោះដោយសារ "មីស្រី" ជាអ្នកប្រាប់ ។ គឺល្បែងបិទពួនស្មោះ, បីដូចជាគេលេងស្វាដណ្ដើរទីដែលប្រព្រឹត្តទៅ ក្នុងបន្ទប់ក៏ចង្អៀតមួយមានគ្រែទៀតផង ។

គឺជាយុទ្ធកម្មដ៏សាហាវ រវាងបុរសនិងស្ត្រីបីដូចនាងមេខលា ដែលប្រយុទ្ធជាមួយយក្ស ដែលចង់ដណ្ដើមយកលែវមនោរាហ៍ពីនាង ដូច្នោះ ... ខ្ញុំគ្មានសំណាងគេចទៅខាងកើតទេ ពីព្រោះ "មីស្រី" នៅប្រចាំទីនោះ ។ តែមួយភ្លែតប៉ុណ្ណោះក្រោយពីរត់យកព្រះអាយុ ដ៏អស់សង្ឃឹមនោះ ។ ខ្ញុំក៏ភ្លាត់ជើងដួល, ហើយឧក្រិដ្ឋជនដែលជា មនុស្សវិជ្ជាជីវៈស្រាប់នោះក៏បាក់មកហើយក៏ចាប់ខ្ញុំជាប់ វាសង្កត់កខ្ញុំផ្ទាច់ នឹងកម្រាលឥដ្ឋ ហើយ "មីស្រី" នោះក៏បោលមកហើយអង្គុយលើពោះខ្ញុំ ។ ខ្ញុំមិនទាន់ធ្វើចលនារើបម្រះអ្វីផង ស្រាប់តែមានម្ជុលមួយចាក់ចូលក្នុងត្រគាករបស់ខ្ញុំស្រេច

បណ្តាលឱ្យខ្ញុំមានសេចក្តីឈឺចាប់ជាខ្លាំង ពីព្រោះ "មីស្រី" ឧក្រិដ្ឋបានបាញ់ថ្នាំចូលក្នុងសាច់ខ្ញុំអស់ ថ្នាំពីបំពង់ ។

- តែប៉ុណ្ណេះ, ស្រេចយើងហើយមីចាបញី ... (ហើយនាង និយាយទៅកាន់សហការីរបស់នាង) បងផ្លេកស្រេចហើយ ...

ប៉ុន្តែផ្លេក ... មិនទាន់លែងដៃអំពីកខ្ញុំនៅឡើយទេ, រួចវានិយាយពាក្យដ៏ទុយិសថាតែបន្តិចទៀត, មីចាបញីឯងនឹងគេងស្រមុកឃ្ញើយនៅក្នុង ឡានពេទ្យរបស់យើង ... ចម្ងាយផ្លូវដែលយើងនឹងធ្វើដំណើរវែងឆ្ងាយណាស់ ... ហើយនៅពេលនោះមីចាបញីឯងនឹងបានទទួល សេចក្តីសុខចប្បាយជាកំពូល ... ខ្ញុំនឹងលែលកឱ្យមីចាបញីឯងបានស្គាល់ឋានសួគ៌ពីនេះរហូតទៅដល់ព្រំដែន ២០ដង, ហើយចាំមើល មើល៍ថាតើចាបញីឯង ហើយនឹងលលកខ្មោច អ្នកណាឈ្មោះអ្នកណា ?

ខ្ញុំគ្មានបានឮសំដីអ្នកតទៅទៀតឡើយ ។ ត្រចៀករបស់ខ្ញុំហ៊ឹងអស់ ។ ភ្នែករបស់ខ្ញុំស្រវាំងមើលអ្វីលែងឃើញ ហើយបន្ទប់ទាំងមូលហាក់បីដូចរវេរាំ ចង្វាក់ទ្វីសដូច្នោះ ។ បន្តិចម្តង១ ដួងវិញ្ញាណខ្ញុំទ្រុឌ ទ្រោមទៅ . . .

៦

## នារីសំពត់ពណ៌ស្វាទុំ

វិចិត្រអង្គុយនៅពីមុខផ្ទាំងគំនូររបស់អ្នក ដោយចិត្តអន្ទះសាជាខ្លាំង ។ តាំងពីពេលនោះមកដល់ឥឡូវនេះ វាជាការហួសចិត្តទៅហើយថា ហេតុអ្វីបានជាកន្និរីពុំទាន់វិលត្រឡប់មកផ្ទះវិញ ? ឬមួយ ក៏នាងមកវិញរួចទៅហើយ ? ប៉ុន្តែជាការធម្មតាទេដោយឋានៈអ្នកជាសង្សាររបស់គេនៅឡើយ, អ្នកមានការអៀនខ្មាសខ្លាំងណាស់ ហើយពុំចង់សួរអនាគតបងថ្លៃស្រីនេះ តាមទូរស័ព្ទឱ្យបានញឹកញាប់ឡើយ ។ អ្នកនឹកដល់សំណាងរបស់អ្នក ដែលឪពុកម្ដាយ របស់អ្នក បានទៅសម្រាន្តនៅឯផ្ទះបុរាណគាត់នោះ, កុំអីអ្នកក៏មានការពិបាកណាស់, ដើម្បីទូរស័ព្ទទាក់ទងជាញឹកញយ, ដោយហេតុថាទូរស័ព្ទនេះនៅក្បែរបន្ទប់សម្រាន្តរបស់គាត់, អ្នកងើយមើលទៅនាឡិការ ប៉ោល : ម៉ោង ១២និង១៥នាទី ... អ្នកក៏រវៃលេខទូរស័ព្ទ ហៅ អនាគតបងថ្លៃរបស់អ្នក ។ នៅពេលដែលគេលើកដៃទូរស័ព្ទឯចុងខ្សែម្ខាងហើយ, ដោយមានជំនឿជឿជាក់ថាកន្និរីសង្សាររបស់អ្នកវិលត្រឡប់មកផ្ទះវិញហើយនោះអ្នកក៏និយាយផ្ទួងថា :

- អូនកន្និរី, មែនទេ ?

- អ្នកណាហ្នឹង ? វិចិត្រឬ ? មិនមែនទេ, កន្និររបស់វិចិត្រឯង មិនទាន់ត្រឡប់មកវិញឡើយ, ធ្វើឱ្យខ្ញុំភ័យសម្បើមណាស់ ! ខ្ញុំឈប់ កែកិច្ចការសិស្សហើយ, ខ្ញុំកំពុងអង្គុយទន្ទឹងផ្លូវ ដូចដែលម្ដាយទន្ទឹង កូនដូច្នោះ ...

- បើដូច្នេះបានន័យថា ... បានន័យថាកន្និរីមានគ្រោះថ្នាក់ មែនទេបងស្រី ?

- តាមខ្ញុំយល់មានតែច្រកនេះឯងដែលយើងអាចសង្ស័យបាន, ពីព្រោះថា កន្ទីរទោះបីទៅគេងផ្ទះមិត្តភក្តិស្រីឯណាក្តី, ឬទៅ គេងផ្ទះអ៊ំក្តី, ដែលតាម ពិតរបៀប ហ្នឹងកម្រមានណាស់ប្រសិន បើមានវិញ, កន្ទីរសុទ្ធតែប្រាប់ខ្ញុំជាមុន ។

សំដីរបស់អ្នកគ្រូ ដែលជាអនាគតបងថ្លៃនេះបានធ្វើឱ្យវិចិត្រនឹកឃើញភ្លាម :

- បងស្រី, កាលដែលកន្ទីរទៅមើលកុននោះ តើនាងស្លៀក ពាក់សំពត់អាវ ពណ៌អ្វីខ្លះ ?

ម៉េចបានជាវិចិត្រសួរបងដូច្នេះ ? កាលដំបូងនាងមកផ្ទះ ហើយមេឃក្តៅ ពេក នាងក៏ផ្លាស់សម្លៀកបំពាក់ពណ៌ខៀវនោះចេញ ព្រោះវាក្រាស់ពេក ។ រួចនាង ស្លៀកពាក់សំពត់អាវពណ៌ស្វាទុំដែលជាក្រណាត់ Popeline Swiss ។ គឺអាវពណ៌ ស្វាទុំណាវិចិត្រ ...

អាវពណ៌ស្វាទុំ ! ព្រះអើយ, បើអ៊ីចឹងបានន័យថាខ្ញុំ ... ខ្ញុំ ... ខ្ញុំបានជួប នឹងកន្ទីរនៅឯ ...

នៅឯណា ?

នៅផ្លូវច្រកងងឹតមួយ ។ ជាមួយនឹងមនុស្សពីរនាក់ទៀតគឺ ប្រុសម្នាក់ ស្រី ម្នាក់ ។ ក៏ប៉ុន្តែដោយខ្ញុំឃើញកន្ទីរស្លៀកពាក់ខោអាវ ពណ៌ខៀវមុននឹងចេញអំពីផ្ទះខ្ញុំ ទៅនោះខ្ញុំក៏ពុំសូវជាយកចិត្តទុកដាក់ ចាប់ភ្លឹកប៉ុន្មានឡើយចំពោះ នារីម្នាក់ទៀត ដែល មានសម្លៀកបំពាក់ ពណ៌ស្វាទុំនេះឯង ។ ខ្ញុំបានបរឡានកាត់តាមនោះ ហើយចោល ភ្នែកមួយភ្លែតតែប៉ុណ្ណោះ, រួចមកខ្ញុំគ្រាន់តែនឹកក្នុងចិត្តថាខ្វះអ្វីមនុស្ស ដែលមានរូប រាងដូចគ្នាមួយគំនរនោះ ។ ក៏ប៉ុន្តែសម្លៀកបំពាក់ពណ៌ស្វាទុំនោះខ្ញុំរលាស់ជំនឿយ៉ាង ឆាប់រហ័សថា នារីដែលនៅឈរជាមួយ នឹងបុរសនិងស្ត្រីនោះពុំមែនជាកន្ទីរឡើយ ...

សេចក្តីស្ងប់ស្ងៀមបានកើតឡើងមួយរយៈកាលនៃគូរសន្ទនាទាំងសងខាងនេះ មើលទំនងប្រហែលជាគេកំពុងរិះគិតទេដឹង ? នៅទីបំផុត ...

- បើដូច្នេះ តាមគំនិតវិចិត្រឯងថានារីដែលវិចិត្រឯងឃើញនៅ ឯច្រកងងឹតនោះគឺជាកន្ទីរ៍មែនទេ ?

- ឥឡូវខ្ញុំស្ទើរតែអស់សង្ស័យហើយ ។ នារីដែលខ្ញុំឃើញនោះ គឺជាកន្ទី ... តើកន្ទីរ៍ទៅកន្លែងច្រកងងឹងនោះជាមួយនឹងមនុស្សពីរនាក់ធ្វើអ្វី ?

- អ្នកណាដឹងបានហ៎ ? ជួនកាលប្រហែលជាកន្ទីរ៍ដើរជាមួយ មិត្តភក្តិរបស់ខ្លួនដែលទើបមានស្វាមីទេដឹង ? ឬ ... ពិបាកស្មាន ណាស់វិចិត្រខ្ញុំក៏មិនអាចនឹងដឹងបានដែរ ។ ប៉ុន្តែទោះបីក្នុងលក្ខណៈ យ៉ាងណាក៏ដោយ , ខ្ញុំជឿជាក់ថា កន្ទីរ៍ប្អូនស្រីខ្ញុំសុទ្ធតែឱ្យដំណឹងមកខ្ញុំជានិច្ច មិនមែនទុកឱ្យខ្ញុំស្ថិតនៅក្នុងសេចក្តីតក់ស្លុត និងភ័យយ៉ាងដូច្នេះទេ ។

ស្ងាត់មួយភ្លែតទំនងជារិះគិតទៀត ។ វិចិត្រក៏ចាប់ផ្តើមនិយាយ ឡើងទៀតថា :

- បើអ៊ីចឹង មានតែវិធីមួយគឺយើងត្រូវតែទៅរកផ្លូវច្រកងងឹត នោះវិញ ។ សូមបងស្រីចាំខ្ញុំនៅឯមុខផ្ទះ ខ្ញុំនឹងបើកឡានទៅទទួលបងស្រីទៅជាមួយដែរ ។

- ភ្លាម, វិចិត្រខ្ញុំចាំជានិច្ច ។

ការសន្ទនាតាមទូរសព្ទក៏ដាច់ត្រឹមនេះ។ ប្រមាណជា១៥នាទី ក្រោយរថយន្តរបស់វិចិត្រក៏បានមកឈប់នៅមុខផ្ទះរបស់អ្នកគ្រូ ។ អ្នកគ្រូក៏ឡើងឡាន, ហើយអាជានេយ្យយន្តនេះក៏បោលទៅមុខឥត សំចៃ ។ ម៉ោង ១២ និង ២០នាទី យើងរំលឹកឃើញគឺនៅម៉ោងនេះឯង ដែលកញ្ញាកន្ទីរ៍បានរវៃទូរស័ព្ទក្នុងវិមានរបស់ឧក្រិដ្ឋ ដើម្បីហៅ បងស្រីរួច ហៅសង្សារគឺវិចិត្រនេះឯង ។ ព្រោះតែហេតុនេះឯង បានទូរស័ព្ទនោះរោទិ៍ឥតមានអ្នកណាឆ្លើយសោះ ។ គឺបានន័យថា ឃ្លាងគ្នានៅតាមដងវិថីឯណោះ,

រថយន្តរបស់វិចិត្របោលដូចព្យុះ សង្ឃរារសំដៅទៅតាមផ្លូវប្រជាធិបតេយ្យ ។ គួរកត់សំគាល់ថាក្នុង ពេលរឿងនេះកើតឡើង, កាលណោះប្រទេសរបស់យើងស្ថិតនៅក្នុងសន្តិសុខនៅឡើយ ។ អាជានេយ្យយន្តបោលទៅមុខ, ហើយក្នុងមួយរំពេចនោះស្រាប់តែវិចិត្រស្ទាក់ស្ទើរពុំដឹងជាបើកទៅតាមផ្លូវណា ទៀត ។

- បងស្រីខ្ញុំពុំបានយកចិត្តទុកដាក់ថាជាច្រកណាមួយទេ ដែលខ្ញុំបានបរកាត់ពីមុនដោយជួបកន្ទីរនោះ, បងស្រីក៏ជ្រាបដែរ ហើយថា ផ្លូវបែកចេញពី មហាវិថីប្រជាធិបតេយ្យនេះមានច្រើនណាស់ ។ តើផ្លូវណាមួយ ,

អ្នកគ្រូដកដង្ហើមធំ :

- បើវិចិត្រមិនដឹងផង តើឱ្យខ្ញុំដឹងយ៉ាងម៉េចទៅហ៏ អ្នកគ្រូ និយាយដោយសម្លេងចង់អស់សង្ឃឹម ។

ក្រោយពីបើកនិងបត់បែន ៥-៦សា, វិចិត្រហាក់ធ្លាក់ទៅក្នុង ការស្រយុតស្រយង់ចិត្តមួយ ។ អ្នកស្តាយខ្លាំងណាស់ពុំគួរធ្វេស ប្រហែសហើយពុំគួរថាឥតច្រកចូលសោះ ។ គឺជាផ្លូវដីក្រហែងក្រហូង ។ ក៏ប៉ុន្តែមានផ្លូវដីក្រហែងក្រហូងដល់ទៅ ១០ ឬ ២០ ឯណោះនៅតាមបណ្តោយមហាវិថីប្រជាធិបតេយ្យ តើផ្លូវណាមួយ ?

ពេលវេលាកន្លងទៅមុខសន្សឹមៗ ក៏ប៉ុន្តែចំពោះវិចិត្រ និងអ្នកគ្រូ រេខា ពេលវេលានេះលឿនហោះដូចព្រួញ ។ ក្រោយពីស្ងៀមមួយសន្ទុះ, ហើយក្នុងសូរស័ព្ទរថយន្តដែលលាន់ខ្ទ័រខ្ទានេះ, វិចិត្រក៏អារកាត់ៗ ថា :

ខ្ញុំគិតថាគួរបងស្រីអញ្ជើញទៅកាន់ប៉ុស្តិ៍ប៉ូលិសមុន, ហើយ ជំរាបគេហូរហែរអំពីរឿងបាត់ខ្លួនរបស់កន្ទីរនេះ រួចសូមឱ្យប៉ូលិស ចេញចាត់វិធានការយ៉ាងណា ដើម្បីឆែកឆេរនិងឃាត់គ្រប់រថយន្ត ទាំងអស់ដែលចេញផុតពីទីក្រុងនេះ ។ ការធ្វើដូច្នេះវាប្រសើរជាជាង មិនធ្វើអ្វីទាំងអស់នោះដែរ ។ ឧបមាថា ឧក្រិដ្ឋជនដែលចាប់រូបនាង

មានបំណងនឹងនាំចេញទៅក្រៅនោះពិតរត់ពុំរួចពីដៃប៉ូលិសឡើយ ។ ឧបមាថាឧក្រិដ្ឋជន បានចាប់នាងដើម្បីសេចក្ដី សប្បាយរបស់វានៅក្នុងទីក្រុង, ការដែលធ្វើដូច្នេះពុំមែនជាឥតប្រយោជន៍ ឡើយចំពោះប៉ូលិស ។ ថាដូច្នេះហើយរថយន្តក៏ឈប់ងក់ មុខនិគមស្នងការដ្ឋាន ទួលទំពូង ។ អ្នកគ្រូក៏ចុះ, ឡានក៏ទៅមុខទៀត ។

រថយន្តរបស់វិចិត្របោល ទៅមុខឥតគោលដៅហើយចេញចូលគ្រប់ច្រកផ្លូវ . . .

តើវិចិត្ររកច្រកនឹងវិមានដ៏អាថិកំបាំងដែលអ្នកស្រមៃក្នុងចិត្តថា, កន្ទីររបស់អ្នកដែលស្លៀកពាក់ពណ៌ក្រហម ឬពណ៌ស្លាទុំនៅទី នោះឃើញដែរឬទេ ?

## ៧

## សំណាងពីអតិតកាល

នៅពេលដែលខ្ញុំ កំពុងតែទ្រុឌទ្រោមគ្រោមអានុភាពថ្នាំសណ្តំ ដែល "មីស្រី" ឧក្រិដ្ឋបានចាក់បញ្ចូលទៅក្នុងសាច់ខ្ញុំនោះខ្ញុំខិតខំទប់ ស្មារតីខ្ញុំកុំឱ្យស្រយុតស្រយង់ហួសហេតុទៅតាមអានុភាពថ្នាំ ។ ក្នុងពេលនោះខ្ញុំបានឮឧក្រិដ្ឋជនទាំងពីរនាក់នេះកំពុងតែនិយាយឆ្លើយឆ្លងគ្នា ៖

"អាស្រី" បងពុំអាចទ្រាំទ្រនឹងអាការផ្សារភ្នែកនេះបានទេ ។ មីចាបញីនេះវាជះម្រេចមួយកញ្ចប់ចូលភ្នែកបងទាំងសងខាង, លុប មុខប៉ុណ្ណោះក៏ឥតផ្លូវដែរប្រហែលជាខ្វាក់ផងក៏ពុំដឹង ... ដូច្នេះតើឱ្យ គិតយ៉ាងដូចម្តេចហា ? បានអ្នកណាបើកបរឡានទៅ ? ពីព្រោះពីទីនេះទៅបាត់ដំបង ហើយពីបាត់ដំបងទៅដល់អូជ្រៅ, "អាស្រី" គិតមើលថា តើត្រូវចំណាយពេលប៉ុន្មានម៉ោង ហើយតើបងបើកបរ យ៉ាងដូចម្តេចបាន បើភ្នែកបងបើកខ្លួនឯងពុំរួចផងនោះ ?

អ៊ីចឹង បងផ្តេកឯងគិតយ៉ាងណាទៅឥឡូវនេះ , បងគិតថាឱ្យ "អាស្រី" ឯងចាក់ ថ្នាំ Morphine ឱ្យបងមួយម្ជុល ដើម្បីឱ្យបងដេកសម្រាក, ឯកិច្ចការនេះគួរ "អាស្រី" ឯងប្រគល់ឱ្យ អាឆ្លូញម្តង ដើម្បីឱ្យវាធ្វើការនេះជំនួសបង, មិនថាអ៊ីចឹង "អាស្រី" ?

"មីស្រី" ឧក្រិដ្ឋស្ទាក់ស្ទើរចិត្ត ហើយក៏រលាស់សំនួរថា ៖

ចុះបើពីទីនេះចេញទៅនោះ បងផ្តេកឯងគិតយ៉ាងដូចម្តេចទៅ ?

នៅកណ្តាលក្រុងមិនជាអ្វីទេ "អាស្រី" ឯងចេះបើកឡានស្រាប់ ហើយតើ "អាស្រី" ឯងបើកបរទៅរកផ្ទះអាឆ្លូញវាក៏ធ្លាប់រួមសហ- ប្រតិបត្តិការជាមួយយើងអ៊ីចឹងដែរ, មានអ្វីដែលថាវាប្រកែក ?

បើអ៊ីចឹងយើងគិតចេញដំណើរឥឡូវមែនទេ ? សម្លេង "មីស្រី" សួរ ។

ត្រូវហើយ "អាស្រី" ទម្រាំយើងលើក "មីចាបញី" បញ្ចូលក្នុង ឡាន, ទម្រាំ "អាស្រី" ឯងចាក់ថ្នាំ Morphine ឱ្យបងបានដេកលក់, ពីព្រោះភ្នែក របស់បងពើតចុកចាប់ណាស់, ទំរាំ "អាស្រី" ឯងទៅ រកអាឆ្លូញទៀត, ឃើញថាពេលវេលានៅពីមុខយើងខ្លីណាស់ហើយ "ចៅហ្វាយ" របស់យើងនឹងមិនអភ័យទោសឱ្យយើងទេ បើយើងចេះតែបណ្តែតបណ្តោយឱ្យយូរថ្ងៃមិនថាអ៊ីចឹង ? ហ៏ ឥឡូវចាត់ការភ្លាមទៅ !

វាទាំងពីរនាក់ក៏យកគ្រែស្នែង របស់ពេទ្យចេញមក ហើយលើក ខ្ញុំដាក់លើគ្រែស្នែងនេះ ។ ថ្វីត្បិតតែកម្លាំងកាយរបស់ខ្ញុំ ចេះតែទ្រុឌទ្រោមទៅៗ ក៏ដោយ, ក៏កម្លាំងចិត្តនឹងមនសិការរបស់ខ្ញុំនៅចងចាំជានិច្ច ។ ដោយសារការប្រឹងទប់ទល់នូវអានុភាពនៃថ្នាំនេះ ត្រចៀកខ្ញុំក៏ ហ៊ឹងឥតបើប្រៀបបាន ។ ឧក្រិដ្ឋជនពិតជានឹងនាំខ្ញុំឆ្លងដែនទៅកាន់ ប្រទេសសៀម ក្នុងគោលបំណងមួយ គឺយកខ្ញុំទៅឱ្យធ្វើពេស្យាកម្ម ។ នារីនៃសលកលោកនេះតែងបានជួបគ្រោះថ្នាក់ អកុសលរបៀបនេះជាច្រើនណាស់ ។ នៅតាមប្រទេសខ្លះៗ នៃសកលោកនេះ, គេ ចាប់យកស្ត្រីទៅធ្វើ "ជំនួញឋានសួគ៌" ហើយការស៊ីគ្រលំរបស់អាជ្ញាធរ នៅឯព្រំដែនក៏មានសន្ធឹកសន្ធាប់ណាស់ដែរ ហើយសារព័ត៌មាន ក្នុងសកលោកនេះតែងតែបានចុះផ្សាយអំពីការបាត់ខ្លួនរបស់ក្រមុំបារាំង អារ៉ាប់, ស៊ុយអែត ឥណ្ឌូនេស៊ី ឬអាមេរិកឡាទិន ជាច្រើន ក្បាល . . .

ទោះបីសព្វថ្ងៃនេះ "ការរត់ពន្ធស្រី" មាសន្ធឹកសន្ធាប់ណាស់ ... ដូច្នេះគួរនារីខ្មែរយើងមានសេចក្តីប្រុងប្រយ័ត្ន ចៀសវាងនូវការដើរម្នាក់ឯង ឬដើរនៅកន្លែង

ស្ងាត់ដោយពុំគប្បី ហើយម្យ៉ាងទៀតការជឿសំដីរបស់បុរសខ្លះៗ ដែលនាងពុំសូវស្គាល់ច្បាស់ ហើយនាងពុំគប្បីទៅជាមួយនឹងបុរសនេះឯទីដ៏ទៃណា ដែលនាងគ្មានអ្វីការពារខ្លួននោះទេ ...

ថ្វីត្បិតតែខ្ញុំហៀបនឹងស្រយុតស្រយង់ទៅក្នុងថិនមិទ្ធ [១] ទៅ ហើយក៏ដោយខ្ញុំ ក៏នៅតែដឹងអំពីចង្វាក់គ្រែស្នែងដែលកំពុងលោត ផ្លោតៗ តាមជំហានជើងនៃឧក្រិដ្ឋជនដែលកំពុងតែសែងខ្ញុំចុះជណ្ដើរ ក្រៅអំពីចលនារលាក់នេះ ខ្ញុំឮសូរសម្លេង "មីស្រី" កំពុងតែបញ្ជា "អាប្រុស" ឱ្យបត់ស្ដាំ ឆ្វេង ឬឱ្យដើរត្រង់ទៅមុខ ។ "អានេះ" ក្លាយ មកជាពពែខ្វាក់ដែរ "មីសេះញី" កំពុងតែតម្រង់ផ្លូវ ។

- - - - - - - - -

[១] ការងងុយដេក

- - - - - - - - -

នៅពេលដែលគេដាក់ខ្លួនចុះ, ច្រមុះរបស់ខ្ញុំធុំក្លិនថ្នាំលាបថ្មីៗ ។ តាមខ្ញុំយល់ គឺជាថ្នាំដែលគេលាបឡានសម្រាប់ដឹងខ្ញុំទៅបរទេសហើយ, គឺឡានពេទ្យ ។ តាមទំនងមើលវាទើបតែនឹងលាបថ្នាំថ្មីៗ, ពុំដឹងជាមែនឬមិនមែនទេ ... ខ្ញុំហៀបនឹងរលត់ស្មារតីនិទ្រាទៅហើយ, ខ្ញុំឮសូរសម្លេង "អាប្រុស" ប្រាប់ "មីស្រី" ថា :

- អញស្ដាយណាស់ ដូចជាមីកន្ទុចឯងដឹងស្រាប់ហើយ ... មីចាបញីនេះមានរូបឆោមស្អាតផុតស្រីទាំងឡាយ ក៏ប៉ុន្តែវាចង្រៃ ភ្នែកអញនេះចុកចាប់ហួសនិស្ស័យនឹងថ្លែង, កុំអីអញទៅលេង ឋានសួគ៌ជាមួយនឹងវាដូចដែលបាន សន្យាជាមួយនឹងវាអម្បាញ់មិញមុន ដែលវាសន្លប់២០ដងយ៉ាងតិច ... មិនអី ទេចាំថ្ងៃត្រង់ដែលអញបានសៀ្វយក៏បានដែរ, វាមិនទៅណាទេ, វានៅតែក្នុងឡានដូច្នេះឯង ហើយជាប់ចំណងទៅទៀត ។

- បានហើយបងផ្លេកប្រយ័ត្នអានូញវាដឹងឮដល់ "ចៅហ្វាយធំ", បងផ្លេកឯងមុខជារកអំបិលប្រឡាក់គ្មានឡើយ ... កាំបិត, កាំភ្លើង, ឡដុតបន្សុះទាំងរស់, បងផ្លេកឯងមិនមែនថាមិនដឹងនោះទេ . . . បងផ្លេកឯងអាចបោក "ចៅហ្វាយ" របស់បងឯងបានដោយគាត់ ខឹងមានថ្ងៃនឹងជាមើលមុខបងឯងវិញ, ក៏ប៉ុន្តែប៉ះពាល់ដល់រឿងស្រីមុន "ចៅហ្វាយ" បងអើយសូម្បីតែផែនដីនេះ ប្រេះជាពីរក៏បងឯងពុំបានសេចក្ដីសុខដែរ ... ម្យ៉ាងទៀតបងឯងដឹងស្រាប់ហើយថា នៅឯម្ខាងព្រំដែនយើងឯណោះ, ការបើ "ស្រទាប់ផ្កា" គ្រែបច័ន្ទទឹកឃ្មុំ នោះមានតម្លៃច្រើនម៉ឺនបាតណាស់ ... ហើយតាមខ្ញុំដឹងមីចាបញីនេះ វានៅក្រពុំបរិសុទ្ធ, មិនដឹងមែនឬមិនមែនឡើយមានតែចៅហ្វាយ យើងទេដែលអាចដឹងបាន, ក្រោយពីភ្លក់រួចហើយ . . .

បានហើយមីកន្ទួចចាក់ថ្នាំឱ្យអញមក ដើម្បីដេកសំរាកមួយ ម៉ោងពីរម៉ោងសិន ចៀសវាងកុំឱ្យភ្នែកអញចុកផ្សាពេក ។ បន្ទាប់ មកអាស្រីឯងបើកឡានទៅរកអានូញឱ្យវាជូនដំណើរម្ដង ។ ចំណែកអញ នៅដេកក្បែរមីចាបញីនេះ ហើយមីស្រីឯងរកវិធីដោះស្រាយ ជាមួយនឹងប៉ូលីស ឬអាជ្ញាធរ ដែលឃាត់ឡានយើងនេះនៅតាមផ្លូវផង .. ថ្នាំ Morphine ដែលអាស្រីឯងចាក់ឱ្យអញ ប្រហែលជាមិនធើបមុន ៣ម៉ោងក្រោយពី បានសម្រាកនោះឡើយ . . . ៣ម៉ោងក្រោយភ្នែកអញប្រហែលជានឹងបាត់ផ្សាហើយមីចាបញីនេះក៏បានដឹងខ្លួនដែរ . . . ដល់ពេលនោះ ស្នេហាដែលវាប្រទាក់ប្រឡាគ្នា គឺបានសប្បាយណាស់ គេមិនដែល ទៅស្នេហាជាមួយមនុស្សម្នាក់ដែលសន្លប់ដូចមីចាបញីនេះទេ, បើអ៊ីចឹង យើងទៅស្នេហាជាមួយខ្មោចស្លាប់មិនប្រសើរជាងឬ ?

ខ្ញុំមានសេចក្ដីឈឺចាប់ នឹងការមើលងាយរបស់សត្វតិរច្ឆាន នេះឥតមានអ្វីប្រៀបផ្ទឹមបាន ។ ដោយអានុភាពថ្នាំសណ្ដំដោយអានុភាព នៃការហ៊ឹងត្រចៀក, ដោយ

អានុភាពនៃកំហឹងខ្ញុំ, ខ្ញុំក៏សន្លប់ភ្លាម មួយរំពេច ឯវិញ្ញាណខ្ញុំក៏ហោះហើរទៅកាន់ពិភព នៃសុបិន ហើយខ្ញុំក៏លែងដឹងអ្វីទៀតឡើយ ...

ខ្ញុំឥតបានដឹងថា "មីស្រី" ឧក្រិដ្ឋជនបើកឡានទៅតាមផ្លូវណា រួចនាំខ្ញុំទៅទីណានោះទេ ។ ខ្ញុំនិទ្រាលង់លក់ហាក់បីដូចជាសាកសពដូច្នោះ ។ ដោយសារកម្លាំងចិត្តដែលខ្ញុំខំទប់នឹងអានុភាពថ្នាំអស់កាលដ៏យូរ, ដូច្នេះនៅពេលដែលខ្ញុំចាញ់វា, គឺចាញ់យ៉ាងទ្រុឌទ្រោមបំផុតដែរ ។ ព្រលឹងរបស់ខ្ញុំហាក់បីដូចជាស្ថិតនៅក្នុងភាពងងឹតសូន្យដែលគ្មានកោះត្រើយ ។ នៅក្នុងគ្រាដែលខ្ញុំសន្លប់ដោយថ្នាំសណ្ដំនេះ, ព្រលឹងរបស់ខ្ញុំហាក់ដូចជាបានឈរនៅលើកោះតូចមួយ ដែលល្មមតែ ខ្ញុំម្នាក់ប៉ុណ្ណោះ នាកណ្ដាលសមុទ្រខៀវក្រមៅដ៏ល្វឹងល្វើយនៅជាប់ នឹងជើងមេឃ ដែលបោកកញ្ច្រោលទៅដោយលលកនឹងពពុះ ខ្វល់ខ្វាញ់នៃត្រីឆ្លាមនិងក្រពើសមុទ្រ ។ កាលដែលខ្ញុំកំពុងស្ថិតនៅក្នុងការដឹងខ្លួនខ្ញុំមានសេចក្ដីភ័យខ្លាចហួសវិស័យនឹងស្មាន ។ អនិច្ចា ! នៅពេល ដែលខ្ញុំកំពុងនិទ្រាលក់ដោយសារអានុភាពនៃថ្នាំសណ្ដំនេះ អារម្មណ៍របស់ខ្ញុំក៏គ្មានសេចក្ដីស្ងប់ដែរ, ក្រពើនឹងត្រីឆ្លាម, ដែលខ្ញុំជានារីឈរ តែម្នាក់ឯងនៅកណ្ដាលសមុទ្រដ៏មានលក្ខណៈគួរឱ្យរន្ធត់នេះ ។

ពេលវេលាពុំដឹងជាកន្លងទៅប៉ុន្មានម៉ោងនោះទេ ក៏ប៉ុន្តែក្នុងភាព សោះសូន្យសុង ដែលព្រលឹងរបស់ខ្ញុំកំពុងតែអណ្ដែតត្រសែតដោយមហិទ្ធិឫទ្ធីនៃថ្នាំ សណ្ដំនោះស្រាប់តែខ្លួនខ្ញុំបានទទួលនូវការទង្គិចមួយ ដ៏ខ្លាំងដោយបណ្ដាលឱ្យខ្ញុំភ្ញាក់បានមួយភ្លែតដែរ ។ គឺហាក់ដូចជាអ្នក ណាម្នាក់មកចាប់ខ្ញុំបោះទៅទង្គិចក្បាលនឹងជញ្ជាំងមួយ ។ មនសិការរបស់ខ្ញុំបានវិលមកឋានពិភពលោកនេះវិញក្នុងមួយភ្លែតនោះ ហើយត្រចៀករបស់ខ្ញុំហាក់ដូចជាបានឮស្នូរកង់ឡានដែល សង្កៀតនឹងផ្ទៃ ថ្នល់ដោយការអូស ។

ក្នុងមួយវិនាទីនេះឯងមនសិការនឹងសម្បជញ្ញៈ ដ៏វាងវៃរបស់ខ្ញុំបានប្រាប់ខ្ញុំឱ្យដឹងថា ខ្ញុំនៅក្នុងរថយន្តពេទ្យនេះនៅឡើយដែលឈប់ដោយបង្ខំចិត្ត ។

នៅក្នុងសភាពអណ្ដែកអណ្ដូងដ៏ល្ងើយៗ នេះ, សោតារបស់ខ្ញុំ ហាក់ឮសូរ ស៊ីរ៉ែន ដែលរោទិ៍នៅក្បែរខ្ញុំនេះ ។ ខ្ញុំខំប្រឹងបើកភ្នែក, ក៏ប៉ុន្តែត្របកភ្នែកខ្ញុំពុំព្រម របើកទៅតាមការប្រឹងរបស់ខ្ញុំសោះ ។ ក៏ប៉ុន្តែទោះបីយ៉ាងនេះក្ដី ខ្ញុំក៏បានដឹងថាខ្ញុំបាន ដេកលង់លក់អស់មួយរយៈកាលហើយ, ហើយបណ្ដាលឱ្យខ្ញុំមានកម្លាំងបន្តិចបន្តួច ឡើងវិញឯថ្នាំសណ្ដំក៏រសាយឥទ្ធិពលរបស់វាខ្លះដែរ ។

ក្នុងពេលជាមួយគ្នានោះ ខ្ញុំឮសូរជំហានមនុស្ស ដែលលោតចុះពីរថយន្តស៊ីរ៉ែន ។ ហើយខ្ញុំឮសូរសម្លេងគំហកខ្លាំងរបស់នរណាម្នាក់ :

- ខ្ញុំជាតំណាងច្បាប់ខ្ញុំបានផ្លុំកញ្ចែហៅឡានរបស់លោកឈប់, ហេតុអ្វីបានជា លោកចចេសបើកល្បឿនពុំព្រមឈប់តាមបញ្ជារបស់ខ្ញុំ ?

ក្នុងពេលនោះខ្ញុំឮសម្លេងបុរសម្នាក់តបវិញ :

- អត់ទោសលោក ខ្ញុំមិនបានឮ ...

- បើមិនបានឮ,

ហេតុអ្វីបានជាពេលដែលឡានខ្ញុំដេញតាមឡានរបស់លោក, ម្ដេចក៏ លោកមិនឈប់ ?

- ខ្ញុំជាបុគ្គលិកពេទ្យភារកិច្ចរបស់ខ្ញុំគឺដឹកអ្នកជំងឺយ៉ាងណាឱ្យ បានឆាប់រហ័ស បំផុត, ករណីកិច្ចរបស់ខ្ញុំមានតែប៉ុណ្ណឹងទេ . . .

ខ្ញុំឮសម្លេងនេះ ខ្ញុំដឹងច្បាស់ថាជាសម្លេងរបស់បុរសថ្មីដែលបាន បើករឡាន ជំនួសអាផ្លែកកំពុងតែដេកលក់ស្រមុកឃ្លើយ ដោយថ្នាំ Morphine ដូចខ្ញុំដែរក៏ពុំដឹង ហើយអាមួយថ្មីនេះប្រហែលជាឈ្មោះអាឆ្លញ, បើតាមសំដីឧក្រិដ្ឋជន ដែលសន្ទនា ជាមួយគ្នា, កាល ដែលវាទើបនឹងសែងខ្ញុំចុះពីលើវិមាន បិសាចនោះ ។

ក្នុងពេលនោះឯងខ្ញុំខំប្រមូលកម្លាំងកាត់នឹងចិត្តទាំងអស់ ដើម្បីនឹងស្រែកអាក្រោសឡើងថា : "មិនមែនទេ ! មិនមែនទេ ! ពួកវា សុទ្ធតែជាឧក្រិដ្ឋជនទាំងអស់ !" ។ ប៉ុន្តែគ្មានសូរសៀងណាផុះចេញ ពីប្រអប់មាត់របស់ខ្ញុំឡើយ ព្រោះតាមពិតខ្ញុំមិនអាចហាមាត់ស្រែករួចទេ, មានតែទឹកចិត្តប៉ុណ្ណោះ ក៏ប៉ុន្តែទឹកចិត្តវាស្ថិតនៅក្នុងបេះដូង ហើយបេះដូងវាស្ថិតនៅក្នុងទ្រូង ដែលជិតស្លឹបគ្មានអ្វីបញ្ចេញមកក្រៅសោះ ។

ខ្ញុំយល់ហើយថាលោកជាពេទ្យ មានភារកិច្ចបំពេញករណីកិច្ចជាពេទ្យ ប៉ុន្តែលោកក៏ជ្រាបដែរថា ខ្ញុំជាប៉ូលិសខ្ញុំក៏មានភារកិច្ច ដើម្បីនឹងពិនិត្យតាមពាក្យបណ្តឹងរបស់មនុស្សខ្លះដូច្នោះដែរ ពីព្រោះខ្វះអ្វីឡានពេទ្យដែលពុំប្រាកដនោះ ?

ពេលនោះសម្លេង "មីស្រី" ឧក្រិដ្ឋក៏បន្លឺយ៉ាងច្បាស់តបនឹងសំដីរបស់ប៉ូលិស :

- លោកមិនឃើញទេឬ ថាពួកខ្ញុំនេះជាពេទ្យ ? មួក អាវស និងឡាន ពេទ្យដែលដឹកអ្នកជំងឺពីរនាក់នៅក្នុងនេះ ពុំមែនបញ្ជាក់ថា ពួកខ្ញុំជាពេទ្យទេឬ ?

សភាពស្ងប់ក៏កើតឡើងអស់រយៈកាល ៣វិនាទី ។ តាមទំនង មើលភ្នាក់ងារប៉ូលិសប្រហែលជាទាល់ប្រាជ្ញាក៏ពុំដឹង ។ ក៏ប៉ុន្តែនៅក្នុង ភាពអស់សង្ឃឹមរបស់ខ្ញុំឮសម្លេងមួយទៀត ដែលជាសម្លេងបុរស សម្លេងនេះពុំអាចបំភ័ន្តខ្ញុំបានទេគឺជាសម្លេងជាទីស្នេហា, គឺជាសម្លេង ដ៏ទន់ភ្លន់, គឺជាសម្លេងរបស់បុរស ម្នាក់ដែលខ្ញុំចងចាំជានិច្ច, គឺបង វិចិត្រ :

- បើអ្នកស្រីជាពេទ្យមែន, ពួកយើងខ្ញុំក៏មិនជំទាស់អីដែរ ក៏ ប៉ុន្តែខ្ញុំសុំមើលមុខអ្នកជម្ងឺផងបានទេ តើអ្នកជម្ងឺនោះជានរណាខ្លះ ? ឈ្មោះអី ?

- លោកដូចជារំលោភពេកហើយ "មីស្រី" ឆ្លើយតប ។ លោក ជាប៉ូលិសលោកជាស៊ីវិល , តែលោកពុំមែនជាពេទ្យទេ ហេតុអ្វីក៏ លោកមក ចង់រើកកាយក្នុងរឿងរបស់ពេទ្យ ?

- អភ័យទោស, បងវិចិត្របន្ត . ខ្ញុំគ្រាន់តែសុំមើលអ្នកជម្ងឺក្រែងខ្ញុំ ស្គាល់ថា អ្នកជម្ងឺនោះគឺជាមនុស្សមួយរូបដែលខ្ញុំបានប្តឹងប៉ូលិស ហើយដែលខ្ញុំកំពុងតាមរក ។ គឺខ្ញុំពុំមែនពិនិត្យរោគអ្នកជម្ងឺនោះទេ ...

ប្រសិនបើខ្ញុំស្រែករួច, ម៉្លេះសមខ្ញុំស្រែកឱ្យបែកទ្រូងដើម្បីប្រាប់ថា : "បងវិចិត្រ, អូននៅទីនេះ ! អូននៅទីនេះ ! " ...

ការស្ងប់ស្ងាត់ក៏កើតឡើង ២-៣វិនាទីទៀត ។ ទីបំផុតសម្លេងខ្ទ័រៗ របស់ប៉ូលិសក៏បន្លឺឡើង :

- យើងខ្ញុំសុំឆែកពិនិត្យមើលអ្នកជម្ងឺក្នុងឡាននេះសិន, ប្រសិន បើពុំមែនជាអ្នកជម្ងឺដែលទាក់ទងនឹងពាក្យបណ្តឹងទេ, យើងខ្ញុំនឹង អនុញ្ញាតឱ្យអ្នកស្រីអញ្ជើញទៅភ្លាម ។ សេចក្តីស្នើសុំក្នុងក្រសួង របស់ខ្ញុំគឺមិនធ្វើឱ្យអ្នកស្រីខាតពេលហួសពី ៥នាទីឡើយ ...

នៅពេលនោះឯងនៅឯក្រោមជើងរបស់ខ្ញុំ, ខ្ញុំឮសូរនរណាម្នាក់ទាញកន្ត្រាក់ទ្វារយ៉ាងខ្លាំង ។ ហើយក្នុងខណៈពេលតែមួយប៉ប្រិចភ្នែកដ៏ស្តើងរបស់ខ្ញុំ ហាក់បានឆ្លុះដល់ដួងកែវនេត្រារបស់ខ្ញុំ ពន្លឺពិលដែលកំពុងជះ ខ្ញុំចង់ស្ទុះក្រោកឡើង ដើម្បីស្រែកអំពាវនាវឱ្យគេជួយខ្ញុំ ។ ក៏ប៉ុន្តែខ្ញុំគ្មានកម្លាំងអ្វីសោះ, ក្រៅអំពីភាពមមើមមាយរបស់ខ្ញុំ ។

នៅពេលនោះ ខ្ញុំឮសូរសម្រែកមួយ :

ឱ អូនកន្និរ៍, អូនកន្និរ៍, អូនកន្និរ៍របស់បង !

ហើយក្នុងខណៈតែមួយខ្ញុំឮស្នូរជំហានជើងដែលគេឡើងមកលើរថយន្តនេះ ហើយស្ទុះមកឱបរាងកាយឥតចលនារបស់ខ្ញុំ ។

ពិតហើយនេះគឺជាសម្លេងរបស់បងវិចិត្រ, បងវិចិត្រដែលខ្ញុំស្រឡាញ់រកអ្វីប្រៀបពុំបានក្នុងលោកនេះ ...

តែប៉ុណ្ណោះ, ខ្ញុំបានរួចខ្លួនវិញហើយ ... តែប៉ុណ្ណោះព្រហ្មចារីរបស់ខ្ញុំមិនត្រូវនរណាក្រៅអំពីបងវិចិត្រហ្មងហែងខ្ទេចខ្ទីហួរខ្ទុះដូចខ្ទឹមដំទេ ឱបអូនឱ្យខ្លាំងមកបងវិចិត្រឱបអូនឱ្យណែនមកបងវិចិត្រ... អូនលែងទៅនរកទៀតហើយ, គឺអូនបានវិលមកឋានសួគ៌ជាមួយនឹងបងវិញ ...

ក្រោយពីបានដឹងថា រាងកាយរបស់ខ្ញុំចាកផុតពីក្រញាំដៃមច្ចុរាជ ដ៏ឃោរឃៅ, ដ៏យង់ឃ្នង, ដ៏សាហាវ, ដ៏ព្រៃផ្សៃហើយ, ខ្ញុំលែងប្រឹង ទាំងខាងផ្លូវចិត្តទាំងខាងផ្លូវកាយទៀតហើយ ។ ខ្ញុំបណ្ដោយឱ្យអានុ ភាពថ្នាំលុកទន្ទ្រានខ្ញុំតទៅទៀតចុះ ហើយខ្ញុំក៏ធ្មេចភ្នែកជាថ្មីទៅកាន់ ពិភពខ្មៅសូន្យសុងដើម្បីសម្រាកកាយ ។

បន្ទាប់ពីនោះមកខ្ញុំឥតបានដឹងអ្វីទៀតឡើយ . . .

## អវសានបទ

ខ្ញុំបើកនេត្រាសន្សឹមៗ ។ ត្របកភ្នែករបស់ខ្ញុំហាក់ដូចជានៅ ធ្ងើយសែន ធ្ងើយនៅឡើយ ... ខ្ញុំប្រទះឃើញរស្មីអារុណោទ័យជះ មកលើកញ្ចក់បង្អួចរបស់ខ្ញុំ ។ ក្នុងខណៈតែមួយនោះ ខ្ញុំស្រមៃថាខ្ញុំ កំពុងស្ថិតនៅវិមានបិសាច, ក្នុងកណ្ដាប់ដៃមច្ចុរាជពីររូប ដែល ប្រាថ្នាយកខ្ញុំទៅប្រហារហើយឱ្យខ្ញុំរងទុក្ខវេទនាទាំងរស់នៅជ្រងោ ... ពេស្យាកម្ម, ពាក្យនេះស្ត្រីទាំងឡាយក្នុងលោកខ្ពើមរអើមរកអ្វី ប្រៀបពុំបាន ថ្វីត្បិតតែថារបរនេះជារបរមួយប្រចាំសតវត្ស និង ប្រចាំសកលលោកនេះក៏ដោយ ។ កើតមកជាស្រីសេចក្ដីប្រាថ្នាដ៏ធំ បំផុតរបស់ខ្លួន, គឺពិធីរៀបមង្គលការជាមួយបុរសមួយរូបដែលនាង ស្រឡាញ់ ។

ខ្ញុំនឹកស្រមៃសព្វគ្រប់បែបយ៉ាង អំពីសេចក្ដីទុក្ខវេទនាដែលជិះ ជាន់លើនារីមួយគ្នាគ្មានអ្វីការពារខ្លួនសោះ ។ ហើយនារីដែលរង គ្រោះនោះគ្មាននរណាក្រៅពីខ្ញុំឡើយ ...

ក្នុងខណៈតែមួយនេះ ស្រាប់តែមនសិការរបស់ខ្ញុំបញ្ជាឱ្យខ្ញុំ ស្រែកឡើងថា :

- "ទេ ! ទេ ! ខ្ញុំមិនទៅទេ . . ."

ម្ដងនេះ ពុំមែនមនសិការរបស់ខ្ញុំទេដែលស្រែក, តាមពិតគឺ សម្លេងរបស់ខ្ញុំស្រែកមែនទែនតែម្ដង ហើយរាងកាយរបស់ខ្ញុំក៏ញ័រ រញ្ជួយដោយសេចក្ដីភិតភ័យរន្ធត់ឥតឧបមា ។

ក្នុងពេលជាមួយគ្នានោះ រាងកាយរបស់ខ្ញុំបានទទួលនូវការឱប មួយដ៏សែនកក់ក្ដៅហើយខ្ញុំឮសម្លេងរបស់បុរសមួយរូបដែលខ្ញុំឥត ភ័ន្តច្រឡំសោះ :

- កន្និរីអូន, រាត្រីកាលដ៏ខ្មៅងងឹតបានកន្លងផុតទៅហើយ នៅសល់តែអរុណោទ័យដ៏ទន់ភ្លន់រមណីយ៉ប៉ុណ្ណោះ ... អូននៅក្នុងមន្ទីរពេទ្យ, អូននៅជិតបង ! ពួកឧក្រិដ្ឋជនពួកឃាតករទាំងពីរនាក់នោះ បានជាប់អន្ទាក់របស់ប៉ូលិសទៅហើយ . . .

តាំងពីមុនមកម្ល៉េះ ថ្វីត្បិតភ្នែកខ្ញុំបើកក្រឡោត ក៏ប៉ុន្តែខ្ញុំពុំបានឃើញបងវិចិត្ររបស់ខ្ញុំទេ ។ នេះជាការធម្មតាទេកាលណាសេចក្ដី ទុក្ខព្រួយមួយមកញាំញី ... ប៉ុន្តែកាលបើបានឮសម្លេងដ៏ទន់ភ្លន់ ត្រជាក់បីដូចទឹកអម្រិតនេះ, ខ្ញុំភ្ញាក់ស្មារតីជាលើកទី២។ ពេលនេះខ្ញុំយល់ច្បាស់ថា កាលពីយប់មិញពេលដែលខ្ញុំហៀបនឹងបណ្ដោយសម្បជញ្ញៈ របស់ខ្ញុំ ឱ្យលិចលង់ក្នុងអានុភាពនៃវេទមន្តថ្នាំសណ្ដំនោះ, ខ្ញុំបានឮសម្លេងបងវិចិត្រ, ខ្ញុំបានឮសម្លេងប៉ូលិស, ដែលគេមកដេញ ស្កាត់ចាប់រថយន្តពេទ្យដែលឧក្រិដ្ឋជន បំរុងដឹកនាំខ្ញុំឆ្លងទៅប្រទេស មួយផ្សេងដើម្បីឱ្យខ្ញុំធ្វើជានារីពេស្យា ...

ខ្ញុំទម្លាក់លំអងក្រសែនេត្រាលើរង្វង់ភក្ត្របងវិចិត្រ ។ គឺបងវិចិត្រមែនពុំមែន "អាប្រុស" ដែលធ្វើទុក្ខបុកម្នេញខ្ញុំ ហើយដែលប្រាថ្នា "ពុះមួយពូថៅឱ្យខ្ញុំដំបៅអស់មួយជីវិត" នោះឡើយ ។

- បងវិចិត្រ ឱបអូនឱ្យតឹងមកបង, កុំឱ្យអូនតក់ស្លុតនឹងភ័យ ខ្លាំងពេក ...

ប្រុសតែប៉ុណ្ណឹងឯង អារឿងដទៃទៀតកុំបញ្ឆោ, តែបើនិយាយ រឿងឱបរិតវិញទុកងារឱ្យចុះ ។ បងវិចិត្រពុំមែនគ្រាន់តែឱបល្មមៗនោះទេ គឺគាត់ឱបយកតែមែនទែន ហើយយ៉ាងយូរបំផុត ... ក្នុង ខណៈតែមួយនោះឯងខ្ញុំពុំបានដឹងខ្លួនថាខ្ញុំនៅទីណានោះទេ ក៏ប៉ុន្តែខ្ញុំ គ្រាន់តែដឹងថាបានឱបរិតបងវិចិត្រវិញ ហើយខ្លួនខ្ញុំហាក់បីដូចជាអណ្តែតទៅឋានសួគ៌ឯណោះ . . .

យូរណាស់ យូរអើយសែនយូរ ... ទើបខ្ញុំដឹងថាបងវិចិត្រលែង ដៃពីប្រាណខ្ញុំ គឺលែងនៅពេលដែលទ្វារបន្ទប់បានរបើកឡើង ។ បង ស្រីរបស់ខ្ញុំដែលជាមាតាទី២ របស់ខ្ញុំ, ស្ទុះចូលមកដោយសេចក្ដីត្រេកអរ . . .

- វិចិត្រ, កន្ទីវដឹងខ្លួនហើយមែនទេ ?

វិចិត្រក្រហមមុខ ដោយមានការអៀន, ហើយយកដៃភ្ញើយ ចង្ការបស់ខ្ញុំ ព្រមទាំងជំរាបបងស្រីខ្ញុំថា :

- បងស្រី ! កន្ទីវដឹងខ្លួនច្បាស់ហើយ, ហើយបានស្រែកហៅ ខ្ញុំឱ្យ . . .

បងយល់ហើយ ។ បើនៅក្នុងលោកនេះសេចក្ដីស្នេហាផ្ដល់តែ ទុក្ខសោក ដូចដែលព្រះពុទ្ធទ្រង់សម្ដែងថា "បេមតោជាយតេសោកា សេចក្ដីលោភទាំងឡាយ កើតមកពីសេចក្ដីស្រឡាញ់មែននោះ " ម្ល៉េះសមបក្សាបក្សីទាំងឡាយ ពុំច្រៀង កញ្ជៀវខ្សៀវខ្វាសប្បាយនោះទេ ! ។

បងស្រីខ្ញុំបែរមុខមកញញឹមដាក់ខ្ញុំហើយសួរថា :

អូនស្រួលខ្លួនមែនហើយឬ ?

ខ្ញុំងក់ក្បាលជាសញ្ញាថា ពិតហើយ ។

♥ ♥

♥

កន្និរីអូន, ហេតុអ្វីបានជាបងហើយនឹងបងស្រីរបស់យើងទៅ សង្គ្រោះអូនទាន់ ? ដំណើរនេះមានដូចតទៅ : ពេលក្រោយដែល បងបានដឹងថាអូនទៅមើលកុនរឿងឈឺចិត្តឆ្អិតទ្រូង នៅឯរោងភាពយន្តបូកគោនោះ, ក្រោយពីបង្អើយផ្ទាំងគំនូររបស់បងហើយ បងក៏ចេញទៅដើម្បីទទួលអូន ហើយឱ្យអូនមានការស្រឡាំងកាំងមួយ ។ ក៏ប៉ុន្តែអនិច្ចា ! បងពុំឃើញអូនសោះ សូម្បីតែកាលណោះម៉ោងជាង ១១ ទៅហើយក៏ដោយ ។ ក្រៅពីបើករថយន្ត ដោយស្ទើរតែអស់កម្លាំងចិត្តនោះ ស្រាប់តែបងបានឃើញស្ត្រីម្នាក់ដែលស្លៀកពាក់ សម្លៀកបំពាក់ពណ៌ក្រហមទុំ ឈរជាមួយនឹងបុរសស្ត្រីពីររូបទៀត នៅឯក្នុងវិមាន ដែលមានរបងចម្រឹងដែកខ្ពស់ៗ ។ បងមិនចាប់ភ្លឹកថាជាអូននោះទេ ពីព្រោះកាលដែលអូនចេញពីផ្ទះបង អូនស្លៀកពាក់សំពត់អាវខៀវ . . .

- ពេលនោះអូនក៏បានឮរថយន្តរបស់បងដែរបងវិចិត្រ ។ សំលេងរថយន្តរបស់បង ទោះបីលាយឡំជាមួយនឹងសម្លេងរថយន្តឯទៀត ១០០គ្រឿងក៏អូនពុំអាចច្រឡំបានដែរ ... ក៏ប៉ុន្តែ អនិច្ចា ! ពេលនោះអានុភាពនៃ ថ្នាំសណ្តំវាធ្វើឱ្យអូនទន់ជង្គង់រួចទៅ ហើយ, អូនស្រែកហៅបងប៉ុន្តែសម្លេង អូនពុំចេញពីបំពង់កសោះ ។

ពេលនោះបងវិចិត្រ ក៏បន្តទៅទៀតថា :

- ហើយរថយន្តរបស់បង ក៏បើកហួសច្រកនោះមក ដោយបងគ្រាន់តែនឹកក្នុងចិត្តថាមានស្រីទី២ម្នាក់ណា រូបរាងដូចអូនតែប៉ុណ្ណោះ ។ ពេលវេលាកន្លងទៅរហូតដល់ទៅម៉ោង ១២ និង៥នាទីយប់ , សេចក្តីសង្ឃឹមចំពោះការវិល ត្រឡប់របស់អូនក៏រលាយខ្សុរដូចអំបិលត្រូវទឹក។ បងដឹងច្បាស់ថាអូនជួបប្រទះនឹងគ្រោះថ្នាក់មួយ, ហើយគ្រោះថ្នាក់ចំពោះនារីដែលមានរូបឆោមដូចអូននេះ គេទាយត្រូវ ១០០០ក្នុង ១០០០ភាគ ។ ប៉ុន្តែតើគេត្រូវធ្វើយ៉ាងដូចម្តេច ។ ដូច្នេះបងត្រូវតែយកការថៃជន្យ

ដែលបងបានឃើញស្រីម្នាក់រូបរាង ដូចអូននោះ យកមកអនុវត្តន៍ជាបឋមសិន ។ ប៉ុន្តែអនិច្ចា, នៅពេល ដែលបងនិងបងស្រីយើងបើករថយន្តដើម្បីស្វះស្វែងរកអូននោះ បងហាក់ដូចជាវង្វេងអស់ហើយ បងរកច្រកផ្លូវដែលបងបានឃើញស្រីម្នាក់ពីល្ងាច ស្លៀកពាក់សំពត់អាវពណ៌ស្វាទុំនោះពុំឃើញសោះ ។ បង ក៏សម្រេចចិត្តឱ្យបងស្រីចូល ទៅឯប៉ុស្តិ៍ប៉ូលិស ដើម្បីជំរាបហេតុការណ៍ដល់ក្រសួងមានសមត្ថកិច្ច ឱ្យជួយធ្វើ អន្តរាគមន៍ ឃាត់រថយន្តទាំង អស់ដែលត្រូវចេញពីទីក្រុង ។ ទីបំផុតនៅពេលឡាន របស់បងបត់បែនតាមផ្លូវគ្រហេងក្រហូងដ៏ច្រើននោះ ស្រាប់តែបងឃើញឡានពេទ្យ មួយបើកពីចម្ងាយយ៉ាងលឿន ហើយបត់ចូលតាមផ្លូវឯមុខ មួយនោះ, គំនិតប្រតិកម្ម របស់បងគឺតាមមើលរថយន្តនេះសិន ។ មែនយានគិលានសង្គ្រោះបានបត់ចូលតាម ច្រកមួយ , ហើយដែលចង្អៀងហ្វារបស់វា បងក៏យល់ច្បាស់ថា គឺជាច្រកដែល កាលពីល្ងាចមិញបងបានឃើញស្រីម្នាក់ស្លៀកពាក់សំពត់អាវពណ៌ស្វាទុំ ។ ការដែល ច្រឡំមកពីរូបអូនលើកនេះគឺច្រកនេះត្រូវគេបិទភ្លើងងងឹតសូន្យ ។ ឡានពេទ្យក្រោយ ពីបានបត់ចូលទៅដល់ក្នុងហើយ, បងឃើញស្រីម្នាក់មកបិទទ្វារដែកនេះវិញ, គឺជាស្រី ដែលប្រដាប់កាយ ដោយឯកសណ្ឋានពេទ្យ សេចក្តីសង្ស័យរបស់បងមានប្រសិទ្ធភាព ណាស់ ... ឡានពេទ្យគេពុំដែលបើកមកសម្ងំនៅទីលាននៃវិមានណាមួយនោះទេ ។ បានជាបងសន្និដ្ឋានដូច្នេះ ព្រោះស្ត្រីដែលបានបើកទ្វារ ឱ្យឡាននេះ ចូលហើយ បានបិទ ទ្វារវិមាននេះវិញ។ បងក៏ចតឡាន នៅកន្លែងងងឹតមួយ ហើយបងរត់សំដៅទៅវិមាន នោះតាមមធ្យោបាយដែលបងសង្ឃឹមថាម្ចាស់វិមាននោះពុំបានដឹងឡើយ, បងដើរឯប ខ្លួននឹងរបងសម្រឹងដែកនៅខាងក្រោយវិមាន ។ ពេលវេលាកន្លង ទៅប្រមាណជា ១៥ នាទីក្រោយបងបានឮសូរ សម្លេងមួយយ៉ាង ខ្ទ័រខ្ទារដែលហែកអាកាសកណ្តាលរាត្រី "អុយ" ...

- ចាំះ បងវិចិត្រ, គឺពេលនោះហើយអូនជះម្រេចមួយកញ្ចប់ចំភ្នែកអាឧក្រិដ្ឋជននោះ ដែលចូលបន្ទប់ប្រាថ្នាបំផ្លាញព្រហ្មចារីអូន . . .

ខ្ញុំពោលដោយក្រហមមុខ ។

បងវិចិត្រនៅស្ងៀម,គាំងសំដីអស់មួយរយៈកាល។ ខ្ញុំក៏ពោលអះអាងឡើងថា :

- អូនឥតខាតបង់អ្វីសោះ ... សូមបងជឿអូនចុះ !

- កាលណោះ បងចង់ស្ទុះចូលទៅ ក៏ប៉ុន្តែគំនិតប្រតិកម្មទី២ បានឃាត់បងជាប់ ។ ធម្មតាការចាប់បំបាត់មនុស្ស, ឧក្រិដ្ឋជនពុំមែន ចាប់មកដើម្បីប្រហារជីវិតភ្លាមនោះទេ ។ គឺដើម្បីធ្វើជាថ្នូរអ្វីមួយ ។ ក៏ប៉ុន្តែប្រសិនបើឧក្រិដ្ឋជនដឹងថាកិច្ចការរបស់ខ្លួនត្រូវបានគេដឹងហើយនោះ, វានឹងសម្លេះជនរងគ្រោះ ដែលខ្លួនបានចាប់មក ។ នេះជាចរិតលក្ខណៈរបស់ឧក្រិដ្ឋជន ។ កាលណោះ គំនិតប្រតិកម្មរបស់បងបំភ្លឺ បងថាមិនយូរទេ, ឧក្រិដ្ឋជននឹងនាំអ្នករងគ្រោះ បញ្ចូលក្នុងរថយន្ត ពេទ្យនេះហើយជាការពិតណាស់ទៀតថាគេមិនដែលនាំអ្នករងគ្រោះទៅដោយឥតចាក់ថ្នាំសណ្តំទេ។ មែនដូចការស្មានរបស់បងមែន, បន្តិចក្រោយមកបងក៏ឃើញមនុស្សពីរនាក់ស្រីម្នាក់ប្រុសម្នាក់, បានសែងអ្នកជម្ងឺម្នាក់ចុះមកគ្របដណ្តប់ ដោយក្រណាត់សរួចបញ្ចូលទៅក្នុងឡានពេទ្យ ។ គំនិតប្រតិកម្មទី ៤ របស់បងឥតភ័ន្តច្រឡំឡើយ ។ អ្នករងគ្រោះនេះប្រហែលជា "កន្និ" ។ ហេតុការណ៍មួយ ធ្វើឱ្យបងឆ្ងល់ គឺថាក្រោយពីបញ្ចូលជនរងគ្រោះទៅក្នុងឡានពេទ្យនេះហើយ, ឡាននេះពុំទាន់ចេញភ្លាមនោះទេ ហើយលុះមួយសន្ទុះក្រោយបងឃើញតែស្រីម្នាក់គត់ដែលបើកបរឡាននេះ ។

បងវិចិត្រ, គឺ "អាប្រុស" នោះវាពុំអាចបើកបរឡានបាន ព្រោះភ្នែករបស់វាក្រហល់ក្រហាយពើតផ្សា បានដោយសារម្រេចមួយ កញ្ចប់ដែលអូនជះចំភ្នែករបស់វា

ដូចអាប៉ោងគេបើកគ្របចាក់ដូច្នោះ វាក៏បញ្ជាឱ្យ "មីស្រី" នោះចាក់ថ្នាំ Morphine មួយម្ទុលដើម្បីឱ្យវាដេកលក់ថ្មីត្បិតតែកម្លាំងកាយរបស់អូនទ្រុឌទ្រោមដោយអានុភាព នៃ ថ្នាំសណ្តំលើកទីពីរនោះ, មនសិការរបស់អូននៅឃ្លាំប្រុងដើងការណ៍ ហើយដឹងហេតុការណ៍ដែលកន្លងទៅទាំងអស់ឥតលោះខាន ។

វិចិត្រក៏បន្តរឿងនេះដូចតទៅ :

- ឡានពេទ្យនេះក៏ចេញពីវិមាន ក្រោយពីស្រីអ្នកបើកបរនេះ បានបិទទ្វារចម្រឹងដែកនេះវិញ ។ បងដែលបានថយខ្លួនមកប្រុងប្រៀបចាំនៅក្នុងរថយន្តរបស់បងស្រេចហើយនោះ, បងក៏ដេញតាមឡាន នេះដោយមិនឱ្យដឹងខ្លួនហើយនិងមិនឱ្យបាត់ដានឡើយ ។ បន្ទាប់មកឡាននេះក៏ឈប់នៅមុខផ្ទះមួយទៀត, ស្រីនោះក៏ឡើងទៅលើផ្ទះនោះ, បីនាទីក្រោយមកបុរសម្នាក់ទៀត ដែលមានឯកសណ្ឋានជាពេទ្យដែរក៏ឡើងមកបើកបរឡាននេះជំនួសនាង ។ ទីបំផុតយានគិលានសង្គ្រោះនេះ ក៏ចេញដំណើរឆ្ពោះទៅផ្លូវដែលទៅគីឡូម៉ែត្រ លេខ ៦ ។ ប៉ុន្តែជាភ័ព្វសំណាងហើយអាស្រ័យដោយមនសិការរបស់ ប៉ូលិសផងនោះ បងឃើញគេឆែកឆេរគ្រប់ផ្លូវចេញទាំងអស់ ហើយនៅឯជិតផ្សារថ្មី បងឃើញឡានប៉ូលិសមួយដែលយាមនៅទីនោះប្រចាំការ ។ បងធ្វើសញ្ញាដៃហើយចង្អុលឡានពេទ្យ ។ ទំនងជា បានដឹងភេរវសញ្ញានេះជាមុនឡានប៉ូលិសក៏បានបំពេញករណីកិច្ចរបស់ខ្លួនគួរឱ្យសរសើរ ។
បន្ទាប់ពីនោះមកអូនក៏បានដឹងសព្វគ្រប់អស់ហើយ, មិនថាអ៊ីចឹង . . . ។

មោងឫស្សី ១០ កក្កដា ១៩៦៩